**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៦១)

ភាគីដាក់ឯកសារ៖ មេធាវីការពារក្តីរបស់ យឹម ទិត្យ

ដាក់ជូន៖ អង្គបុរេជំនុំជម្រះ

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 23-Mar-2020, 09:19
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ **សម្ងាត់/Confidential**

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**ការឆ្លើយតបរបស់ យឹម ទិត្យ ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹង បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

---

**<u>ដាក់ដោយ÷</u>**

**សហមេធាវី**

សូ មូស្សេទ្ធី
Suzana TOMANOVIĆ

**<u>ផ្ញើជូន÷</u>**

**ចៅក្រមអង្គបុរេជំនុំជម្រះ÷**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម Olivier BEAUVALLET

ចៅក្រម ន័យ ថុល

ចៅក្រម BAIK Kang Jin

ចៅក្រម ហួត វុទ្ធី

ចៅក្រមបម្រុង ប៉ែន ពេជ្រសាលី

០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ៦១)

ចៅក្រមបម្រុង Steven J. BWANA

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោកស្រី Brenda J. HOLLIS

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង ០០៤**

## សេចក្តីផ្តើម

១. លោក **យឹម ទិត្យ** តាមរយៈសហមេធាវីការពារក្តីរបស់ខ្លួន ("មេធាវីការពារក្តី") សូមដាក់ការឆ្លើយតបរបស់ យឹម ទិត្យ ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ការឆ្លើយតប" និង "ចម្លើយតប")។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិគួរត្រូវបានបដិសេធចោល។ អង្គបុរេជំនុំជម្រះបានសម្រេចជាឯកច្ឆ័ន្ទនៅក្នុងសំណុំរឿង ០០៤/២ ថា មិនមានមូលដ្ឋានគតិយុត្តិ ដើម្បីឱ្យសហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយពីរដាច់ពីគ្នាឡើយ។ នេះក៏មានន័យថា ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅក្នុងសំណុំរឿង ០០៤ ខុសច្បាប់ ដែលធ្វើឱ្យដីកានេះចាត់ទុកថាត្រូវបានមោឃភាព និងមិនមានសុពលភាព[1]។ ជាលទ្ធផល សារណាទាំងអស់ស្តីពីអង្គសេចក្តីនៃដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅពេលនេះមិនពាក់ព័ន្ធឡើយចំពោះកិច្ចដំណើរការនីតិវិធីបច្ចុប្បន្នដែលធ្វើឱ្យ*បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងសំណុំរឿង ០០៤* ("បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ") និងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ក្លាយជាឥតបានការ។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះគួរបដិសេធដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលមានវិការៈ ហើយ (១) បដិសេធទាំងស្រុង និងលើកលែងការចោទប្រកាន់ប្រឆាំងនឹង លោក យឹម ទិត្យ (២) បញ្ជូនសំណុំរឿងត្រឡប់ទៅសហចៅក្រមស៊ើបអង្កេតវិញ ដើម្បីចេញដីកាដំណោះស្រាយតែមួយរួមគ្នា ឬ (៣) វាយតម្លៃសំណុំរឿង ០០៤ ដោយផ្ទាល់ ហើយចេញដីកាដំណោះស្រាយផ្ទាល់របស់អង្គបុរេជំនុំជម្រះ។

## ប្រវត្តិនីតិវិធី

២. មេធាវីការពារក្តីបញ្ចូលប្រវិត្តិនីតិវិធី ដែលមាននៅក្នុង *ចម្លើយតបរួមរបស់ យឹម ទិត្យ ទៅនឹងសេចក្តីសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ* [2] នៅក្នុង

[1] ដីកាដំណោះស្រាយ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382។

[2] *ចម្លើយតបរួមរបស់ យឹម ទិត្យ ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ* ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D378/5 កថាខណ្ឌ ១៤-១០៥។

*បណ្តឹងឧទ្ធរណ៍របស់លោក យឹម ទិត្យ ប្រឆាំងនឹងដីកាដំណោះស្រាយចំនួនពីរនៅក្នុងសំណុំរឿង 004*[3] និងនៅក្នុង *បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង 004*[4]។

៣. នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ *បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើកលែងការចោទប្រកាន់ យឹម ទិត្យ* (ឯកសារ *D381*)[5]។

៤. នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ *បណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ ក្នុងសំណុំរឿង 004*[6]។

៥. នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ មេធាវីការពារក្តីបានដាក់ *សំណើបន្ទាន់របស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់ សម្រាប់ចម្លើយតបរបស់គាត់ ទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ*[7]។ ស.ព.អ បានឆ្លើយតបនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩[8]។

៦. នៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០២០ អង្គបុរេជំនុំជម្រះបានចេញ *សេចក្តីសម្រេចលើសំណើសុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់ចម្លើយតបពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង*

---

[3] *បណ្តឹងឧទ្ធរណ៍របស់លោក យឹម ទិត្យ ប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរនៅក្នុងសំណុំរឿង 004* ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/18 ("បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយចំនួនពីរ") កថាខណ្ឌ ៤-១០។

[4] *បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង 004* ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D382/22 កថាខណ្ឌ ៣-៩។

[5] *បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើកលែងការចោទប្រកាន់ យឹម ទិត្យ (D381)* ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/19។

[6] *បណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ ក្នុងសំណុំរឿង 004* ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/20។

[7] *សំណើបន្ទាន់របស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់ចម្លើយតបរបស់គាត់ ទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/21 និង D382/23។

[8] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើសុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់របស់ យឹម ទិត្យ ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង 004* ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/23 និង D382/2។

*០០៤*[9]។

៧. នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៤*[10]។

## ការឆ្លើយតប ៖ បណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ត្រូវបានចាត់ទុកជាឥតបានការ

៨. បណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាំងមូល ត្រូវបានចាត់ទុកថាឥតបានការ ដោយសារតែ (១) អង្គបុរេជំនុំជម្រះបានសម្រេចជាឯកច្ឆ័ន្ទ ក្នុងសំណុំរឿង ០០៤/២ ថា មិនមានមូលដ្ឋានគតិយុត្តិសម្រាប់ឱ្យសហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយពីរឡើយ (២) ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅក្នុងសំណុំរឿង០០៤ ត្រូវបានមោឃភាព និងគ្មានសុពលភាព ដែលធ្វើឱ្យ (៣) មូលដ្ឋាននីមួយៗនៃបណ្តឹងឧទ្ធរណ៍លើអង្គសេចក្តីនៃដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងចម្លើយតបចំពោះមូលដ្ឋានទាំងអស់នេះ នាពេលនេះមិនពាក់ព័ន្ធចំពោះកិច្ចដំណើរការនីតិវិធីបច្ចុប្បន្នឡើយ។

## I. ការចេញដីកាដំណោះស្រាយពីរ មិនមានមូលដ្ឋានគតិយុត្តិឡើយ

៩. ចៅក្រមអង្គបុរេជំនុំជម្រះបានចុះហត្ថលេខាលើសេចក្តីសម្រេចជាឯកច្ឆ័ន្ទក្នុងសំណុំរឿង ០០៤/២ ដែល "ប្រកាសថា ការចេញដីកាដំណោះស្រាយពីរ ដែលផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេត គឺខុសច្បាប់ ហើយរំលោភបំពានទៅលើក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក"[11]។

១០. អង្គបុរេជំនុំជម្រះបានសម្រេចថា សហចៅក្រមស៊ើបអង្កេត "បានប្រព្រឹត្តកំហុសអង្គច្បាប់ដ៏

---

[9] *សេចក្តីសម្រេចលើសំណើសុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់ចម្លើយតបពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៤* ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២០ ឯកសារ D381/24 និង D382/26។

[10] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៤* ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ ឯកសារ D382/27 ('ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ')។

[11] សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 និង D360/33 ('សេចក្តីពិចារណា សំណុំរឿង ០០៤/២') ទំព័រ ៦១។

ធំធេង"[12] ដោយ "ចេញដីកាដំណោះស្រាយពីរផ្សេងគ្នា ផ្ទុយគ្នាក្នុងពេលតែមួយ ដែលមានធ្លាប់មានពីមុនមក នៅក្នុងសំណុំរឿងតែមួយ"[13] ហើយថា សហចៅក្រមស៊ើបអង្កេតបាន "រំលោភបំពានទៅលើក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ប្រាសចាកពីតួនាទីខ្ពស់បំផុតរបស់ពួកគេ និងបង្កើតជាស្ថានភាពគតិយុត្តិដែលមានធ្លាប់មាន ដែលធ្វើឱ្យប៉ះពាល់ដល់មូលដ្ឋានសំខាន់ៗនៃអង្គភាពតុលាការរបស់ពួកគេ"[14]។ អង្គបុរេជំនុំជម្រះ "ប្រកាសថ្កោលទោសយ៉ាងច្បាស់លាស់ចំពោះការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើប្រព័ន្ធច្បាប់របស់ អ.វ.ត.ក" ហើយសម្រេចថា សហចៅក្រមស៊ើបអង្កេត បាន "រំលោភបំពានទៅលើមូលដ្ឋានផ្ទាល់នៃប្រព័ន្ធច្បាប់ អ.វ.ត.ក"[15]។

១១. អង្គបុរេជំនុំជម្រះបានសម្រេចយ៉ាងច្បាស់ និងដោយគ្មានភាពស្រពិចស្រពិលថា ក្រោមក្របខ័ណ្ឌច្បាប់ អ.វ.ត.ក ដីកាដំណោះស្រាយចាំបាច់ត្រូវតែជាសេចក្តីសម្រេចតែមួយ ហើយក្របខ័ណ្ឌនេះមិនអនុញ្ញាតឲ្យមានការចេញដីកាដំណោះស្រាយដាច់ពីគ្នាឡើយ[16]។ អង្គបុរេជំនុំជម្រះសម្រេចថា មាត្រា ៦៧(១) នៃវិធានផ្ទៃក្នុង "ចែងច្បាស់ថា" សហចៅក្រមស៊ើបអង្កេត "ត្រូវ" បញ្ចប់កិច្ចស៊ើបសួរដោយចេញ "ដីកាដំណោះស្រាយ *មួយ ថាត្រូវ* ចោទប្រកាន់ និងបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ *ឬ* លើកលែងការចោទប្រកាន់"[17]។ អង្គបុរេជំនុំជម្រះពិចារណាឃើញថា សទ្ទានុក្រមរបស់វិធានផ្ទៃ

[12] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៨៨ និង៨៩។

[13] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៨៨។

[14] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៨៩។

[15] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១០០ និង១០២។

[16] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១២០ ដល់១២១។

[17] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១២១ (អក្សរទ្រេត គឺសង្កត់ធ្ងន់បន្ថែមលើឯកសារដើម)។ ក្របខណ្ឌគតិយុត្តិ អ.វ.ត.ក បានចែងពីការគាំទ្របន្ថែម។ តាមមាត្រា ៥(៤) នៃកិច្ចព្រមព្រៀងរវាង អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តី នៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើង នៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ('កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក') ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ សហចៅក្រមស៊ើបអង្កេតត្រូវបានតម្រូវឱ្យ "សហការគ្នា ដើម្បីឈានទៅដល់ការឯកភាពគ្នាមួយក្នុងការស៊ើបអង្កេត"។ តាមមាត្រា ២៣ថ្មី នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ដែលរួមជាមួយច្បាប់វិសោធនកម្ម ដែលបានប្រកាសឱ្យប្រើ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (នស/រកម/១០០៤/០០៦) ('ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក') ការស៊ើបអង្កេត "គឺជាការទទួលខុសត្រូវរួមគ្នារបស់ចៅក្រមពីរនាក់"។ អត្ថបទនៃវិធាន ១៤ នៃវិធានផ្ទៃក្នុងមានន័យថា សហចៅក្រមស៊ើបអង្កេត ត្រូវបំពេញកិច្ចស៊ើបសួររួមគ្នា ហើយមានសិទ្ធិអំណាចដូចគ្នា ហើយបទប្បញ្ញត្តិនេះមិនបានយោងទៅរកសហចៅក្រមស៊ើបអង្កេត ដែលបំពេញកិច្ចតែម្នាក់ឯង ហើយចេញ

ក្នុងបានចែងថា "ដីកាដំណោះស្រាយសំដៅទៅលើដីកាចុងក្រោយដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ នៅពេលបញ្ចប់ដំណើរការស៊ើបសួរ ដែលអាចជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងចោទប្រកាន់"[18]។ អង្គបុរេជំនុំជម្រះក៏បានផ្តល់សំអាងហេតុផងដែរថា បញ្ញត្តិបកស្រាយនៅក្នុងវិធាន ១(២) នៃវិធានផ្ទៃក្នុង "មិនបានផ្តល់មូលដ្ឋានគតិយុត្តិគ្រប់គ្រាន់ ដើម្បីទាត់ចោល ឬកាត់បន្ថយគោលការណ៍ស្នូលនៃការឯកភាពគ្នា [...] ឬទាមទារអំណាចក្នុងការបំពេញកិច្ច នៅពេលដែលផលប៉ះពាល់ដោយការអនុវត្តសិទ្ធិអំណាចបែបនេះ អាចមានទំនាស់ជាមួយគោលការណ៍ទាំងអស់នេះ"[19]។ អង្គបុរេជំនុំជម្រះបានសន្និដ្ឋាន ដោយសង្កត់ធ្ងន់ថា៖

> កំហុសដែលសហចៅក្រមស៊ើបអង្កេត បានប្រព្រឹត្តនៅក្នុងសំណុំរឿងនេះ ធ្វើឱ្យខូចខាតដល់មូលដ្ឋាននៃប្រព័ន្ធចម្រុះ និងមុខងារដ៏ត្រឹមត្រូវរបស់ អ.វ.ត.ក។ ទោះបីជាបញ្ហានៅចំពោះមុខ មានភាពធ្ងន់ធ្ងរ និងផុយស្រួយក្តី ប៉ុន្តែសហចៅក្រមស៊ើបអង្កេត នៅតែអនុញ្ញាតឱ្យខ្លួនឯង ចេញដីកាដំណោះស្រាយដែលមានសំអាងហេតុតិចតួច គួរឱ្យកត់សម្គាល់ ដើម្បីផ្តល់យុត្តិកម្មដល់សកម្មភាពរបស់ខ្លួន ដោយគ្រាន់តែរម្លឹកអំពី សេចក្តីសម្រេចរបស់ខ្លួនមួយ នាពេលកន្លងមកប៉ុណ្ណោះ។ ជាពិសេស អង្គជំនុំជម្រះយល់ឃើញថា ជារឿងគួរឱ្យរំខានខ្លាំង ដែលដីកាសម្រេចដាច់ពីគ្នានេះ ត្រូវបានចេញនៅថ្ងៃតែមួយ មួយភាសា ដោយមានការប្រកាសយ៉ាងច្បាស់ដោយសហចៅក្រមស៊ើបអង្កេតទាំងពីរថា ពួកគាត់បានឯកភាពគ្នាលើការចេញដោយខុសច្បាប់នូវដីកាដំណោះស្រាយដាច់ពីគ្នា ហើយផ្ទុយគ្នានេះ។ អង្គជំនុំជម្រះយល់ថា ការអនុវត្តដោយខុសឆ្គងរបស់សហចៅក្រមស៊ើបអង្កេត នៅក្នុងករណីនេះ បង្កគ្រោះថ្នាក់ដល់ប្រព័ន្ធគតិយុត្តិទាំងមូល ដែលគាំទ្រដោយរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ។ គួរឱ្យភ្ញាក់ផ្អើល ចៅក្រមស៊ើប

---

ដីកាដំណោះស្រាយ (គួរឱ្យកត់សម្គាល់គឺលក្ខខណ្ឌតម្រូវ វិធាន ១៤(៤) នៃវិធានផ្ទៃក្នុង ដែលថា ការចេញដីកាដំណោះស្រាយមួយ គឺជាសកម្មភាពដែលត្រូវតែ "អនុវត្តដោយរួមគ្នា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងវិធានផ្ទៃក្នុងនេះ)។ ជាចុងក្រោយ មិនមានការយោងនៅត្រង់ចំណុចណាមួយកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក, ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឬវិធានផ្ទៃក្នុង ដែលចែងអំពីលទ្ធភាពនៃការចេញជាឯកតោភាគី ដោយសហចៅក្រមស៊ើបអង្កេតនូវដីកាដំណោះស្រាយដាច់ពីគ្នា។ សូមមើល បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការចេញដីកាដំណោះស្រាយពីរ កថាខណ្ឌ ២២ ដល់៣០។

[18] សេចក្តីពិចារណា សំណុំរឿង ០០៤/២ កថាខណ្ឌ ១២១ ដកស្រង់សទ្ធានុក្រម វិធានផ្ទៃក្នុង ទំព័រ ១២៩ (អក្សរទ្រេតគូសបញ្ជាក់បន្ថែមលើឯកសារដើម)។

[19] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១២១។

> អង្កេតបាន "ដឹងអំពីបញ្ហា" ដែលអាចកើតឡើងដោយសារតែដីកាដំណោះស្រាយដែលដាច់ពីគ្នា ជាពិសេស នៅដំណាក់កាលបណ្តឹងឧទ្ធរណ៍នោះ [...]។[20]
>
> អង្គបុរេជំនុំជម្រះសម្តែងការសោកស្តាយ និងថ្កោលទោសយ៉ាងខ្លាំងចំពោះស្ថានភាពគតិយុត្តិដែលមានធ្លាប់មានពីមុន ដោយសារតែសកម្មភាពរបស់សហចៅក្រមស៊ើបអង្កេតបានបង្កឡើងចំពោះកិច្ចដំណើរការនីតិវិធីបច្ចុប្បន្នរបស់ អ.វ.ត.ក [...]។[21]

១២. ការសម្រេចជាឯកច្ឆ័ន្ទរបស់អង្គបុរេជំនុំជម្រះ នៅក្នុងសំណុំរឿង ០០៤/២ ចាំបាច់ត្រូវអនុវត្តដូចគ្នាចំពោះសំណុំរឿង០០៤។ វិធាន ២១ នៃវិធានផ្ទៃក្នុងកំណត់អំពីសច្ចភាពផ្លូវច្បាប់នៅក្នុងកិច្ចដំណើរការនីតិវិធី អ.វ.ត.ក[22]។ ក្រុមប្រឹក្សាជំនុំជម្រះដដែលនេះបានស្តាប់សវនាការលើបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង០០៤ ហើយសំណុំរឿងទាំងពីរជួបប្រទះស្ថានភាពនីតិវិធីដូចគ្នានៃដីកាដំណោះស្រាយដែលផ្ទុយគ្នា។ ការសម្រេចជាឯកច្ឆ័ន្ទ និងច្បាស់លាស់របស់អង្គបុរេជំនុំជម្រះ បានតម្កល់

---

[20] *ដូចដើងទំព័រខាងលើ* កថាខណ្ឌ ១២៣ (អក្សរទ្រេតគូសបញ្ជាក់បន្ថែម)។

[21] *ដូចដើងទំព័រខាងលើ* កថាខណ្ឌ ១២៤។

[22] អង្គបុរេជំនុំជម្រះបានពិចារណាថា អង្គបុរេជំនុំជម្រះក៏ "ត្រូវធានាថា "ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធី ប្រកបដោយតម្លាភាពគ្រប់ពេលក្នុងដំណាក់កាល នៅមុនពេលជំនុំជម្រះ"។ សេចក្តីពិចារណា សំណុំរឿង ០០៤/២ កថាខណ្ឌ ៥១ ដកស្រង់វិធាន ២១។ "ចំណុចជាសារវ័ន្តមួយនៃវិធានច្បាប់ គឺ គោលការណ៍សច្ចភាពគតិយុត្តិ ដែលតម្រូវផងដែរថា នៅពេលដែលតុលាការសម្រេចជាស្ថាពរទៅលើបញ្ហាមួយ ការសម្រេចនេះមិនគួរបណ្តាលឲ្យមានបញ្ហាចោទឡើងឡើយ" តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស *Brumărescu* ***តទល់នឹង*** *Romania*, សំណើសុំលេខ 28342/95 សាលក្រម ថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៩ កថាខណ្ឌ ៦១។ តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស *Kehaya* និង *Others* ***តទល់នឹង*** *Bulgaria* សំណើសុំលេខ 47797/99 និង 68698/01, សាលក្រម ថ្ងៃទី១២ ខែមករា ឆ្នាំ២០០៦ កថាខណ្ឌ ៦១។ តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស *Ryabykh* ***តទល់នឹង*** *Russia* សំណើសុំលេខ 52854/99 សាលក្រម ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៣ កថាខណ្ឌ ៥១។ "ក្នុងករណីមានការដាច់ចេញពីគ្នាក្នុងការអនុវត្តបទប្បញ្ញត្តិច្បាប់ ដែលមានភាពប្រហាក់ប្រហែលគ្នាខ្លាំង ចំពោះបុគ្គលនៅក្នុងក្រុម ដែលសឹងតែដូចគ្នាបេះបិទ បញ្ហានៃសច្ចភាពគតិយុត្តិ នឹងកើតមានឡើង"។ តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស *Ştefănică* និង *Others* ***តទល់នឹង*** *Romania* សំណើសុំលេខ 38155/02 សាលក្រម ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១០ កថាខណ្ឌ ៣៧ (ការដកស្រង់ផ្ទៃក្នុង ត្រូវបានលុបចោល)។ ការជំនុំជម្រះសម្រេចដែលមិនស៊ីសង្វាក់គ្នាអំពីបណ្តឹងដែលប្តឹងដោយបុគ្គលដែលស្ថិតក្នុងស្ថានភាពប្រហែលគ្នា នឹងនាំទៅដល់ស្ថានភាពមិនប្រាកដប្រជា ដែលធ្វើឲ្យទំនុកចិត្តរបស់សាធារណជន ចំពោះតុលាការ បានថយចុះ ហើយនឹងដកហូតសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ពីបុគ្គល។ សូមមើល *ដើងទំព័រខាងលើ* កថាខណ្ឌ ៣៨។

ទទួលករណីរបស់មេធាវីការពារក្ដីនៅក្នុងបណ្ដឹងឧទ្ធរណ៍របស់ខ្លួន ប្រឆាំងនឹងការចេញដីកាដំណោះស្រាយពីរ[23]។ នាពេលនេះ មិនមែនជាការជំទាស់ទៅហើយដែលថា ដីកាដំណោះស្រាយពីរដែលរងការជំទាស់ ដែលជាកម្មវត្ថុនៃបណ្ដឹងឧទ្ធរណ៍សំណុំរឿង០០៤ មិនមានមូលដ្ឋានណាមួយនៅក្នុងក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ឡើយ។

## II. ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបានមោឃភាព និងគ្មានសុពលភាព

១៣. អានុភាពនៃការសម្រេចជាឯកច្ឆ័ន្ទរបស់អង្គបុរេជំនុំជម្រះគឺថា ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបានមោឃភាព និងគ្មានសុពលភាព។ វាគឺជាច្បាប់យ៉ាងសាមញ្ញដែលថា ដីកាសម្រេចមួយ ដែលមិនមានមូលដ្ឋានគតិយុត្តិ គឺជាមោឃភាព មានន័យម្យ៉ាងទៀតថា គោលបំណង និងចេតនារបស់ លែងមានអត្ថិភាពទៀតហើយ[24]។

១៤. ជាការពិតណាស់ថា កិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក ចាំបាច់ត្រូវមាន អនុលោមតាមច្បាប់ជាធរមាន[25]។ ដូចដែលអង្គបុរេជំនុំជម្រះបានទទួលស្គាល់ វិធាន ៦៧ នៃវិធានផ្ទៃក្នុង គឺជាច្បាប់ជា

---

[23] បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយចំនួនពីរ កថាខណ្ឌ ២ "នៅពេលជ្រើសរើសចេញដីកាដំណោះស្រាយ នៅក្នុងសំណុំរឿង ០០៤ ចំនួនពីរផ្ទុយគ្នា និងដោយឡែកពីគ្នាបែបនេះ ទាំង ស.ច.ស.ជ និង ស.ច.ស.អ បានអនុវត្តផ្ទុយពីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា [...] ច្បាប់ស្ដីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ [...] និងវិធានផ្ទៃក្នុង។ ដីកាដំណោះស្រាយដែល ស.ច.ស ទាំងពីរបានដាក់ជូន ត្រូវតែទទួលបានការបដិសេធ ដោយសារវិការៈនីតិវិធី អនុលោមតាមវិធាន ៦៧(២) នៃវិធានផ្ទៃក្នុង។ មេធាវីការពារក្ដីសន្និដ្ឋានថា អ.ប.ជ ត្រូវតែអន្តរាគមន៍នាពេលនេះ ដើម្បីបិទបញ្ចប់កិច្ចស៊ើបសួរពិតប្រាកដ សម្រាប់លោក យឹម ទិត្យ ស្របទៅតាមសិទ្ធិរបស់លោក និងដើម្បីការពារសិទ្ធិជាមូលដ្ឋានរបស់លោក ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌"។

[24] វចនានុក្រមច្បាប់ Black's Law Dictionary បានកំណត់និយមន័យ *nullius juris* ថា "គ្មានអានុភាពគតិយុត្តិ" មោឃៈ (*void*) ថា "គ្មានអានុភាពផ្លូវច្បាប់" និង សាលក្រមមោឃៈថាជា "សាលក្រមគ្មានអានុភាពផ្លូវច្បាប់ អាចត្រូវបានអះអាងថា អសុពលភាព ដោយភាគីណាមួយដែលសិទ្ធិរបស់ពួកគាត់ ត្រូវទទួលរងផលប៉ះពាល់ នៅពេលណា និងទីកន្លែងណាក៏បាន ទោះដោយផ្ទាល់ ឬដោយប្រយោលក្ដី។ ចាប់តាំងពីពេលចាប់ផ្ដើមសាលក្រមមោឃៈ បន្តមានលក្ខណៈមោឃៈទាំងស្រុង។ សាលក្រមបែបនេះ មិនអាចទទួលបានការអះអាងគាំទ្រផ្ដល់បត្យាប័ន ឬក៏ចូលជាធរមាន ក្នុងលក្ខណៈ ឬកម្រិតណាមួយបានឡើយ" Garner, B., [Ed.] *Black's Law Dictionary*, 9th edition, ទំព័រ ៩២១, ១១៧៣, ១៧០៩។

[25] មាត្រា ១៣(១) នៃកិច្ចព្រមព្រៀងស្ដីពីការបង្កើត អ.វ.ត.ក ចែងពីការការពារសិទ្ធិរបស់ជនជាប់ចោទ អនុលោមតាមមាត្រា ១៤ និង១៥ នៃកតិកាសញ្ញាអន្តរជាតិ ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ 999 UNTS 171

ធរមានសម្រាប់ការចេញដីកាដំណោះស្រាយ[26]។

១៥. តាមវិធាន ៦៧(២) នៃវិធានផ្ទៃក្នុង ដីកាបញ្ជូនរឿងទៅជំនុំជម្រះ "ត្រូវចាត់ទុកជាមោឃៈដោយមានកំហុសនីតិវិធី" ប្រសិនបើដីកានេះមិនបានកំណត់ "អត្តសញ្ញាណនៃជនជាប់ចោទ ការបង្ហាញអំពីអង្គហេតុ និងការកំណត់ប្រភេទបទល្មើស ដោយសហចៅក្រមស៊ើបអង្កេត ក្នុងនោះមានទាំងបទប្បញ្ញត្តិនៃបទឧក្រិដ្ឋដែលពាក់ព័ន្ធ និងប្រភេទនៃការទទួលខុសត្រូវព្រហ្មទណ្ឌ"[27]។ ដោយសារតែភាពជាក់លាក់នៃលក្ខខណ្ឌនៅក្នុងវិធាន ៦៧(២) នៃវិធានផ្ទៃក្នុង និងពាក្យ "មោឃៈ" មិនមែនអាចមោឃៈបាន ព្រមទាំងលក្ខណៈនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលមានវិការៈនីតិវិធី មិនមានអ្វីជាចម្ងល់ទៀតឡើយដែលថា ដីកាដំណោះស្រាយ ដែលមិនបានចេញដោយគោរពតាមយ៉ាងតឹងរ៉ឹងទៅនឹងច្បាប់នីតិវិធីរបស់ អ.វ.ត.ក ត្រូវជាមោឃៈ និងមិនមានសុពលភាព។ អ្នកតាក់តែងវិធាន ៦៧ នៃវិធានផ្ទៃក្នុង អាចមិនបានប្រមើលមើលនូវរាល់ការបត់បែនថ្មីៗមិនធ្លាប់មាននៃកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក ក្តី ប៉ុន្តែ មិនមែនសម្រាប់ស្ថានភាពខុសច្បាប់ដែលសហចៅក្រមស៊ើបអង្កេតបានចោទប្រកាន់បញ្ជូនទៅជំនុំជម្រះ និងលើកលែងការចោទប្រកាន់ នៅក្នុងពេលតែមួយនោះទេ ដូច្នេះហើយ មានចន្លោះប្រហោងនៅក្នុងវិធាន ៦៧ នៃវិធានផ្ទៃក្នុង។ បើទោះបីជានៅក្នុងវិធាន ៦៧ នៃវិធានផ្ទៃក្នុង មិនមានការយោងទៅស្ថានភាពទាល់ច្រកផ្នែកនីតិវិធី ដូចដែល

---

('កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ')។ មាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា "បុគ្គលគ្រប់រូបមានសិទ្ធិទទួលបានសវនាការជាសាធារណៈ និងដោយយុត្តិធម៌ ដោយតុលាការមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង ដែលបង្កើតឡើងដោយច្បាប់"។ សូមមើលផងដែរ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៥ ថ្មី ចែងពីការអនុវត្តការធានាការពារអប្បបរមា នៅក្នុងមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ មាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងថា ការជំនុំជម្រះនៅ អ.វ.ត.ក "ត្រូវប្រព្រឹត្តទៅឱ្យបានត្រឹមត្រូវ [...] ទៅតាមនីតិវិធីជាធរមាន"។ វិធាន ២១ នៃវិធានផ្ទៃក្នុងចែងបន្ថែមថា "ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាល ទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង"។

[26] សេចក្តីពិចារណា សំណុំរឿង ០០៤/២, ទំព័រ ៦១។

[27] វិធាន ៦៧(២) នៃវិធានផ្ទៃក្នុង "ដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះត្រូវបញ្ជាក់អំពីអត្តសញ្ញាណនៃជនជាប់ចោទ ការបង្ហាញអំពីអង្គហេតុ និងការកំណត់ប្រភេទបទល្មើសដោយសហចៅក្រមស៊ើបអង្កេត ក្នុងនោះមានទាំងបទប្បញ្ញត្តិនៃបទឧក្រិដ្ឋដែលពាក់ព័ន្ធ និងប្រភេទនៃការទទួលខុសត្រូវព្រហ្មទណ្ឌ"។

ចៅក្រមអង្គបុរេជំនុំជម្រះកំពុងជួបប្រទះក្តី តែវិធាននេះបានចែងយ៉ាងច្បាស់ថាដីកាដំណោះស្រាយដែលមិនមានមូលដ្ឋាននៅក្នុងច្បាប់នីតិវិធីរបស់ អ.វ.ត.ក គឺមោឃៈ និងគ្មានសុពលភាព។

១៦. ការបកស្រាយបទប្បញ្ញត្តិនៃវិធាន ៦៧(២) នៃវិធានផ្ទៃក្នុង ស្តីពីការធ្វើមោឃភាពដីកាដំណោះស្រាយដែលមានវិការៈផ្នែកនីតិវិធី រួមទាំងចន្លោះប្រហោងដែលមានផងនោះ ចាំបាច់ត្រូវធ្វើឡើង ឲ្យស្របជាមួយនឹងវិធានបកស្រាយច្បាប់ស៊ីវិល។ បើតាមអង្គជំនុំជម្រះតុលាការកំពូល វិធានបកស្រាយទាំងនេះ "ធ្វើការពិចារណាលើពាក្យពេចន៍ នៃបទប្បញ្ញត្តិ ការដាក់បញ្ចូលក្នុងប្រព័ន្ធ រួមទាំងការជាប់ទាក់ទិនទៅនឹងគោលការណ៍សំខាន់ៗ ដែលជាមូលដ្ឋានគ្រឹះ និងគោលបំណងនៃគោលការណ៍នេះ"[28]។

១៧. ក្រៅពីវិធាន ៦៧(២) នៃវិធានផ្ទៃក្នុង ក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក មិនមានចែងអំពីវិធាន ឬគោលការណ៍ជាក់លាក់ណាផ្សេងទៀតសម្រាប់ការធ្វើមោឃភាពដីកាដំណោះស្រាយឡើយ។ ដើម្បីបកស្រាយឲ្យបានត្រឹមត្រូវចំពោះវិធាន ៦៧(២) នៃវិធានផ្ទៃក្នុង នៅក្នុង "ប្រព័ន្ធ" នៃការធ្វើមោឃភាពក្នុងកិច្ចដំណើរការនីតិវិធី មុនពេលជំនុំជម្រះនៅ អ.វ.ត.ក វិធាននេះចាំបាច់ត្រូវបកស្រាយនៅក្នុងបរិបទនៃបទប្បញ្ញត្តិនៃវិធាន ៧៦ នៃវិធានផ្ទៃក្នុងស្តីពីការធ្វើមោឃភាពនៅក្នុងអំឡុងពេលស៊ើបអង្កេត។ តាមវិធាន ៧៦(១) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតត្រូវបានតម្រូវឲ្យជូនដំណឹងដល់ភាគីនានាអំពីផ្នែកណាមួយនៃកិច្ចដំណើរការនីតិវិធី ដែលសហចៅក្រមស៊ើបអង្កេតចាត់ទុកថាជាមោឃៈ។ វិធាន ៧៦ (២) បានផ្តល់សិទ្ធិដល់ភាគីនានាក្នុងការដាក់សំណើសុំមោឃភាពទៅសហចៅក្រមស៊ើបអង្កេត នៅមុនពេលបិទបញ្ចប់ការស៊ើបសួរ ហើយស្នើសុំដល់សហចៅក្រមស៊ើបអង្កេតឲ្យប្តឹងទៅអង្គបុរេជំនុំជម្រះ។ វិធាន ៧៦(៧) ចែងថា វិការៈនីតិវិធីនៅក្នុងការស៊ើបអង្កេតនឹងត្រូវកែសម្រួលដោយដីកាដំណោះស្រាយ ហើយការកែសម្រួលវិការៈនីតិវិធីដោយដីកាដំណោះស្រាយគឺ "ជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍"។ អ្នកតាក់តែងវិធាន ៦៧ នៃវិធានផ្ទៃក្នុង បានរៀបចំយន្តការមោឃភាពទាំងអស់នេះ ដោយប្រមើលមើលថា ការធ្វើមោឃភាពនៅមុនពេលជំនុំជម្រះអាចធ្វើឡើងតែក្នុងអំឡុងពេលស៊ើបអង្កេតប៉ុណ្ណោះមិនមែនក្រោយពេលស៊ើបអង្កេតទេ។អ្នកតាក់តែងមិនអាចប្រមើលមើលពីភាពចាំបាច់សម្រាប់នីតិវិធីក្នុងការជំទាស់ទៅនឹងមូលដ្ឋាន

[28] សំណុំរឿង ០០២/០១ *សេចក្តីសម្រេចលើបណ្តឹងសាទុក្ខផ្ទាល់មាត់របស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់* ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១១ ឯកសារ E50/3/1/4 កថាខណ្ឌ ៣១។

ផ្លូវច្បាប់នៃការចេញដីកាដំណោះស្រាយនោះឡើយ[29]។

១៨. ដើម្បីបកស្រាយដោយត្រឹមត្រូវចំពោះវិធាន ៦៧(២) នៃវិធានផ្ទៃក្នុង ខ្លឹមសារនៃវិធាន ៧៦ បានគាំទ្រថា *គោលការណ៍ និងគោលដៅជាមូលដ្ឋានយ៉ាងសំខាន់របស់ប្រព័ន្ធ* សម្រាប់ការធ្វើមោឃភាពនៅមុនពេលជំនុំជម្រះ គឺដើម្បីធានាថា ដីកាសម្រេច ឬកិច្ច ដែលមានវិការៈផ្នែកនីតិវិធី របស់សហចៅក្រមស៊ើបអង្កេត គឺជាកម្មវត្ថុនៃការធ្វើមោឃភាពដោយអង្គបុរេជំនុំជម្រះ។ ទាំងជាភាសាបារាំង និងភាសាអង់គ្លេស សម្រាប់វិធាន ៧៦(៥) នៃវិធានផ្ទៃក្នុង ពាក្យពេចន៍ដែលមានន័យដូចគ្នា 'annulment' និង 'cancellation' ត្រូវបានប្រើប្រាស់ជំនួសគ្នាទៅវិញទៅមក[30]។ '*annuler*' ជាភាសាបារាំងមានន័យថា "ទុកចោលមួយកន្លែង ប្រកាសថាមោឃៈ"[31] ចំណែកពាក្យ 'cancellation' គឺជាសទិសន័យនៃពាក្យ 'annulation' មានន័យថា "លុបចោលកិច្ចមួយ ដែល

---

[29] តាមពិតទៅទស្សនៈចៅក្រម នៅក្នុងអង្គបុរេជំនុំជម្រះនៃ អ.វ.ត.ក បានទទួលស្គាល់ថា កិច្ចដែលបានធ្វើឡើងដោយគោរពទៅតាមនីតិវិធីដែលមិនស្របច្បាប់ នឹងក្លាយជាមោឃៈ "សវនាការ ឬសេចក្តីសម្រេចដ៏យុត្តិធម៌មួយ នឹងមិនត្រឹមតែពាក់ព័ន្ធនឹងសិទ្ធិដឹងអំពីអង្គហេតុ និងអង្គច្បាប់ ដែលចោទប្រកាន់ចំពោះខ្លួន និងសិទ្ធិដាក់សារណា ឬសិទ្ធិផ្តល់ចម្លើយក្នុងតុលាការប៉ុណ្ណោះទេ វានឹងរួមទាំងសិទ្ធិទទួលបានភាពយុត្តិធម៌លើនីតិវិធីផងដែរ។ ក្នុងន័យនេះ ភាពយុត្តិធម៌លើនីតិវិធី រួមបញ្ចូលនីតិវិធីដែលមានតម្លាភាព និងស្របច្បាប់ ដែលសិទ្ធិ និងកាតព្វកិច្ច ត្រូវបានផ្តល់ជូន សម្តែងចេញ និងអនុវត្តបានយ៉ាងសមស្រប។ នៅក្នុងវិធីនេះ យើងសង្ឃឹមទុកយ៉ាងជាក់ច្បាស់ថា បញ្ហានេះនឹងត្រូវដោះស្រាយ ក្នុងវិធីមួយជាក់លាក់ សមស្រប និងពិតប្រាកដ។ ប្រសិនបើតុលាការមិនទទួលបានសិទ្ធិអំណាច នោះតុលាការឬចៅក្រម មិនមានអំណាចកែប្រែនីតិវិធី ដែលបានចែងទុក ជាផ្លូវនៃការពន្លឿននីតិវិធី ឬដើម្បីហេតុផលណាមួយផ្សេង ដែលខុសច្បាប់ឡើយ។ ករណីនេះវាធ្វើឲ្យនីតិវិធីមានភាពអយុត្តិធម៌យ៉ាងខ្លាំង ហើយរាល់កិច្ចទាំងឡាយណាដែលបានធ្វើឡើង ក្នុងនីតិវិធីមិនត្រឹមត្រូវតាមផ្លូវច្បាប់ដូច្នេះ នឹងនាំឲ្យមានមោឃភាព"។ សំណុំរឿង ០០២ *សាលដីកាលើបណ្តឹងឧទ្ធរណ៍ លើដីកាសម្រេចរួមរបស់ សហចៅក្រមស៊ើបអង្កេតលេខ D250/3/3 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០និងដីកាសម្រេចលេខ 250/3/2 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ លើការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី* ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០ ឯកសារ D250/3/2/1/5 មតិយោបល់របស់ចៅក្រម ប្រាក់ គឹមសាន និងចៅក្រម Rowan Downing ស្តីពីការប្រកាសមិនទទួលយក ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានទទួលស្គាល់រួចហើយ កថាខណ្ឌ ១៣។

[30] វិធាន ៧៦(៥) នៃវិធានផ្ទៃក្នុងជាភាសាបារាំង យោងទៅរក 'les parties annulées sont cancellées' និង '[a]près annulation ou cancellation […]'

[31] F.H.S. Bridge, *The Council of Europe French-English Legal Dictionary*, Council of Europe Publishing, ឆ្នាំ ១៩៩៤ ទំព័រ ១៦។

បានសរសេរជាលាយលក្ខណ៍អក្សរ"[32]។ តាមវិធាន ៧៦(៥) នៃវិធានផ្ទៃក្នុង កិច្ចដែលមានវិការៈនីតិវិធី ដែលត្រូវបានធ្វើមោឃភាព ឬលុបចោល លែងមានតទៅទៀតហើយ ដោយកិច្ចនេះត្រូវបានដកចេញពីសំណុំរឿង ហើយត្រូវបានហាមឃាត់មិនឲ្យទាញសេចក្ដីសន្និដ្ឋានណាមួយពីកិច្ចនោះ ដើម្បីប្រឆាំងជាមួយភាគីឡើយ[33]។ នីតិវិធីមោឃភាពនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងមាត្រា ២៨០ និងមាត្រា ២៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងមាត្រា ១៧៤ និង២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង[34]។

១៩. ការអះអាងថា ដីកាដំណោះស្រាយ ដែលចេញដោយខុសច្បាប់ មានវិការៈនីតិវិធី នៅក្នុងអត្ថន័យនៃវិធាន ៦៧(២) នៃវិធានផ្ទៃក្នុង មានការគាំទ្របន្ថែមទៀតនៅក្នុងយុត្តាធិការជាតិ និងអន្តរជាតិ។ អង្គបុរេជំនុំជម្រះបានអនុម័តយកវិធីសាស្ត្របកស្រាយមួយ ដែលបន្ទាប់ពីអនុវត្តវិធាននៃការបកស្រាយជាបទដ្ឋានចំពោះក្របខណ្ឌគតិយុត្តិ អ.វ.ត.ក ហើយ អង្គបុរេជំនុំជម្រះនឹងពិនិត្យមើលលើ

---

[32] យោងទៅការបទអត្ថាធិប្បាយរបស់សាស្ត្រាចារ្យ Jean-Paul Doucet, ការលុបចោល (*cancellation*) ត្រូវបានកំណត់និយមន័យជាកិរិយាសព្ទបារាំងថា *biffer*: 'CANCELLATION (Canceller): Cf. Abolition, Nullité. Du latin "cancellare": biffer. Terme juridique visant le fait d'annuler un acte juridique d'une manière matérielle : en le biffant, en le raturant ou en le lacérant.' *Dictionnaire de Droit Criminel*, 'Cancellation,' *អាចរកបាននៅគេហទំព័រ* https://ledroitcriminel.fr/dictionnaire/lettre_c/lettre_c_can.htm (ចូលមើលចុងក្រោយថ្ងៃទី១១ ខែមីនា ឆ្នាំ២០២). A publicly available French dictionary defines *cancellation* as: 'Fait d'annuler un acte en effaçant ce qui est écrit. Signifie également "annulation".' Linternaute, Dictionnaire Française, 'Cancellation,' *អាចរកបាននៅ គេហទំព័រ* https://www.linternaute.fr/dictionnaire/fr/definition/cancellation/ (ចូលមើលចុងក្រោយថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០)

[33] អង្គបុរេជំនុំជម្រះបង្គាប់ "ការលុបចោល និងដកចេញ" ផ្នែកដែលមានវិការៈនីតិវិធីនៃកិច្ចស៊ើបសួរ ចេញពីសំណុំរឿងនៅក្នុងសាលដីកាលើសំណើរបស់ យឹម ទិត្យ សុំធ្វើមោឃភាពឯកសារស៊ើបអង្កេត ដែលធ្វើឡើងដោយ *Paolo STOCCHI* ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧ ឯកសារ D351/1/4 កថាខណ្ឌ ៣៦ និង ទំព័រ ១៧។

[34] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ២៨១ ក្រោយធ្វើមោឃភាពរួច សភាស៊ើបសួរអាច បង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ, ដកសមត្ថកិច្ចចៅក្រមស៊ើបសួរ ហើយបញ្ជូនសំណុំរឿងទៅ ចៅក្រមស៊ើបសួរម្នាក់ផ្សេងទៀត ឬបន្តការស៊ើបសួរដោយខ្លួនឯងលើរឿងនោះ"។ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ២០៦ "ក្រោយមោឃភាពរួច សភាស៊ើបសួរអាចផ្ទេរសំណុំរឿងមកខ្លួនឯងផ្ទាល់ និងបន្តនីតិវិធីអនុលោមទៅតាមលក្ខណៈដូចមានចែងក្នុងមាត្រា ២០១, ២០២ និង ២០៤ ឬបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរដដែល ឬ ចៅក្រមស៊ើបសួរផ្សេងទៀត ដើម្បីបន្តកិច្ចស៊ើបសួរ"។ [Légifrance Translation] *សូមមើលផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ២០៨ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ១៧៤។

នីតិវិធីកម្ពុជា ហើយបន្ទាប់មកនីតិវិធីនៅកម្រិតអន្តរជាតិ[35]។

២០. នៅក្នុងយុត្តាធិការច្បាប់ស៊ីវិល ក្រៅពីច្បាប់កម្ពុជា និងបារាំង មានការកំណត់ដោយច្បាប់ថា ដីកាសម្រេចដែលចេញដោយខុសច្បាប់ គឺជាមោឃៈ ហើយជាលទ្ធផល មិនមានអានុភាពគតិយុត្តិឡើយ។ ឧទាហរណ៍ នៅសាធារណរដ្ឋកូរ៉េ "ការជំនុំជម្រះជាសាធារណៈ ត្រូវបានបដិសេធចោលដោយសាលក្រម [...] ក្នុងករណីដែលនីតិវិធីសម្រាប់បង្កើតការជំនុំជម្រះជាសាធារណៈ មោឃៈដោយសារតែមូលហេតុដែលនីតិវិធីនេះផ្ទុយពីបទប្បញ្ញត្តិច្បាប់"[36]។ នៅក្នុងឧទាហរណ៍មួយទៀត នៅប្រទេសលីប៊ី មោឃភាពកើតឡើងនៅពេលដែលមិនមានការគោរពប្រតិបត្តិតាមច្បាប់ និងនៅពេលពេលនីតិវិធីមួយត្រូវបានចាត់ទុកថាគ្មានសុពលភាព "ផលប៉ះពាល់ទាំងអស់កើតចេញដោយ

---

[35] អង្គបុរេជំនុំជម្រះបានសម្រេចថា វិធានផ្ទៃក្នុងគឺជាប្រភពនីតិវិធីជាគោលការណ៍នៅ អ.វ.ត.ក ហើយក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា "គួរយកមកអនុវត្ត ក្នុងករណីមានបញ្ហាចោទណាមួយ ដែលវិធានផ្ទៃក្នុងមិនមានចែងតែប៉ុណ្ណោះ" សំណុំរឿង ០០២ *សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព* ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ ឯកសារ D55/I/8, កថាខណ្ឌ ១៤ ដល់១៥។ ក្នុងករណីដែលនីតិវិធីព្រហ្មទណ្ឌកម្ពុជា "ពុំអាចដោះស្រាយបានចំពោះបញ្ហាពិសេសណាមួយ" អង្គជំនុំជម្រះអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបង្កើតឡើងក្នុងកម្រិតអន្តរជាតិ *សូមមើល* កិច្ចព្រមព្រៀងស្ដីពីការបង្កើត អ.វ.ត.ក មាត្រា ១២(១)។ ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក មាត្រា ៣៣ថ្មី វិធាន ២ នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ* សំណុំរឿង ០០២/០១ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ១១៨ ដល់១២៦។ អង្គបុរេជំនុំជម្រះចាត់ទុកការបកស្រាយត្រឹមត្រូវលើពាក្យ "រួចខ្លួនជាស្ថាពរ" នៅក្នុងមាត្រា ១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ អង្គបុរេជំនុំជម្រះបានកំណត់ "គោលការណ៍នៃការបកស្រាយដែលគេបានទទួលស្គាល់" ពាក់ព័ន្ធនឹងការបកស្រាយលក្ខន្តិកៈ និងលិខិតុបករណ៍លាយលក្ខណ៍អក្សរទាំងអស់ ដោយកត់សម្គាល់ថា "ត្រូវប្រកាន់ខ្ជាប់អត្ថន័យនៃពាក្យតាមវេយ្យាករណ៍ និងតាមន័យធម្មតា លើកលែងតែថាវាអាចនាំឱ្យមានភាពមិនសមហេតុផល ឬភាពមិនស៊ីសង្វាក់គ្នាជាមួយលិខិតុបករណ៍នោះ"។ នៅក្នុងកថាខណ្ឌ ១១៨ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា កិច្ចព្រមព្រៀងស្ដីពីការបង្កើត អ.វ.ត.ក, ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង មិនមានចែងអំពីការហាមឃាត់ ចំពោះការកាត់ទោសពីរដង និងមិននិយាយអំពីអានុភាពនៃការផ្ដន្ទាទោសពីមុនទៅលើនីតិវិធីនៅចំពោះមុខ អ.វ.ត.ក នោះទេ ដោយអង្គជំនុំជម្រះសម្រេចថា "អនុលោមតាមមាត្រា ១២ នៃកិច្ចព្រមពព្រៀង និងមាត្រា ៣៣ ថ្មី នៃច្បាប់បង្កើត អ.វ.ត.ក អង្គបុរេជំនុំជម្រះនឹងពិនិត្យក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា [...]"។ អង្គបុរេជំនុំជម្រះបន្តពិនិត្យមើលលើក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា នៅក្នុងកថាខណ្ឌ១១៩ ដល់១២៤ ហើយសម្រេចថា អត្ថន័យធម្មតានៃមាត្រា ១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនអនុវត្តចំពោះការផ្ដន្ទាទោសឡើយ។ អង្គបុរេជំនុំជម្រះងាកទៅស្វែងរកគោលការណ៍ណែនាំក្នុងបទដ្ឋាននីតិវិធីនៅកម្រិតអន្តរជាតិ។

[36] សាធារណៈរដ្ឋកូរ៉េ ច្បាប់នីតិវិធីព្រហ្មទណ្ឌ ច្បាប់លេខ ៩៧៦៥ ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៩ មាត្រា ៣២៧(២)។

ផ្ទាល់ពីនីតិវិធីបែបនេះ ក៏ត្រូវបានចាត់ទុកថាគ្មានសុពលភាពដូចគ្នា [...]"[37]។

២១. តាមការវិភាគរបស់មេធាវីការពារក្តីទៅលើយុត្តាធិការច្បាប់ស៊ីវិល ច្បាស់ណាស់ថា គោលការណ៍ដែលថា ដីកាសម្រេចដែលចេញដោយខុសច្បាប់ គឺមោឃៈ ហើយជាលទ្ធផលមិនមានអានុភាពគតិយុត្តិនោះ គឺជាច្បាប់សាមញ្ញ ជាគោលការណ៍មួយដែលមានប្រជាប្រិយ ហើយចាក់ឫសយ៉ាងមាំ ដែលគ្រប់គ្នាបានដឹងឮជាទូទៅ និងកម្រមានការជំទាស់ណាស់។ ជាការពិតមិនអាចប្រកែកបាន យុត្តិសាស្ត្រដែលថៅក្រមធ្វើការពិភាក្សាសម្រេចទៅលើអត្ថន័យនៃគោលការណ៍នេះ គឺកម្រ ឬស៊ឹងមិនមានតែម្តង[38]។

២២. ចំណុចនេះក៏ត្រូវបានចាត់ទុកផងដែរថាជាច្បាប់សាមញ្ញនៅក្នុងយុត្តិសាស្ត្រច្បាប់កុំមិនឡូ។ បើទោះបីជាគោលការណ៍ដែលថា ដីកាសម្រេចដែលចេញដោយខុសច្បាប់ គឺមោឃៈ ហើយការមិនមានអានុភាពគតិយុត្តិ ជាញឹកញាប់ត្រូវបានលើកឡើងនៅក្នុងយុត្តិសាស្ត្រក្តី គោលការណ៍នេះកម្រត្រូវបានជំទាស់ណាស់។ ឧទាហរណ៍ នៅក្នុងយុត្តិសាស្ត្រសហរដ្ឋអាមេរិក "អានុភាពនៃការសម្រេចថា សាលក្រមមួយមោឃៈ ត្រូវបានកំណត់ច្បាស់។ ហាក់ដូចជាថា កិច្ចដំណើរការនីតិវិធីបែបនេះ មិនបានកើតមានឡើង ហើយការសម្រេចគ្រាន់តែជាមោឃភាព ហើយភាគីស្ថិតក្នុងស្ថានភាពដដែល ដូចជាមិនមានការសម្រេចដែរ"[39]។ អ្វីដែលបង្ហាញពីគោលការណ៍នេះ គឺនៅក្នុង

[37] ក្រមនីតិវិធីព្រហ្មទណ្ឌប្រទេស លីប៊ី និងច្បាប់បន្ថែម ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៥៣ មាត្រា ៣០៤ និង៣០៩។

[38] ទោះបីជាមេធាវីការពារក្តីមានស្មារតីប្រុងប្រយ័ត្នខ្ពស់ និងព្យាយាមអស់ពីសមត្ថភាព ក្នុងការស្វែងរកយុត្តិសាស្ត្រពីយុត្តាធិការច្បាប់ស៊ីវិល អំពីផលវិបាកនៃសេចក្តីសម្រេចខុសច្បាប់ក្តី មេធាវីការពារក្តីមិនអាចស្វែងរកពីប្រភពដែលខ្លួនមាននូវការយោងក្នុងសេចក្តីសម្រេចរបស់តុលាការ ពន្យល់អំពីផលវិបាកផ្លូវច្បាប់នៃដីកាសម្រេចដែលចេញដោយខុសច្បាប់ឡើយ។

[39] *Romito តទល់នឹង Maxwell*, 227 N.E.2d, 223, 224 (Ohio ឆ្នាំ១៩៦៧) "អានុភាពនៃការសម្រេចថា សាលក្រមមួយមោឃៈ ត្រូវបានកំណត់យ៉ាងច្បាស់លាស់។ យ៉ាងណាក៏ដោយ កិច្ចដំណើរការនីតិវិធីបែបនេះមិនបានកើតឡើងដូចនេះទេ។ សាលក្រមត្រូវបានមោឃភាព ហើយភាគីនានាស្ថិតក្នុងស្ថានភាពដដែល គឺដូចជាមិនមានសាលក្រមនោះ (ការដកស្រង់ផ្ទៃក្នុងត្រូវបានលុបចោល)។ "ការមិនមានការផ្តន្ទាទោសមុនមក នៅក្នុងករណីបច្ចុប្បន្ននេះ គឺជាផ្នែករួមមួយនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌដែលមានស្រាប់ ហើយនៅពេលដែលកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌដែលមានស្រាប់បែបនេះ ត្រូវបានប្រកាសថាមោឃៈ ការមិនមានការផ្តន្ទាទោសពីមុនក៏មោឃៈផងដែរ។ អ្នកដាក់ញត្តិត្រូវស្ថិតក្នុងស្ថានភាពដដែល ដូចពីមុនចំពោះកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌដែលមានស្រាប់ តាមការផ្តន្ទាទោសពីមុនដែលមានសុពលភាព"។ *សូមមើលផងដែរ State តទល់នឹង Bezak*, 868 N.E.2d 961, 963 (Ohio ឆ្នាំ២០០៧) ដកស្រង់ *Romito តទល់នឹង Maxwell*: "Bezak មិនត្រូវបានជូនដំណឹងអំពីទោសនៃការគ្រប់គ្រងលើដំណែងដែលទំនេរ នៅក្នុងសវនាការផ្តន្ទាទោសគាត់។ ជាលទ្ធផល ការផ្តន្ទាទោសដែលបាន

សាលដីកាសម្រេចរបស់តុលាការឧទ្ធរណ៍ព្រហ្មទណ្ឌរដ្ឋតិចសាស់ ក្នុងរឿងក្ដី *Ex parte Seidel* ដែលដីកាសម្រេចលើកលែងរបស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង "ទាំងស្រុង" ត្រូវបានចាត់ទុកថា "លើសពីអញ្ញត្រកម្មនៃកិច្ចធម្មតា ដែលសកម្មភាពនោះគឺស្ថិតក្រៅកម្រិតនៃវិធាន ឬនីតិវិធីណាមួយ ដែលនៅនាពេលនោះ"[40]។ តុលាការបានសន្និដ្ឋានថា "សកម្មភាពរបស់ចៅក្រមសាលាដំបូង ហួសពីការរំលោភបំពានទៅលើនីតិវិធីច្បាប់" ហើយថា "សកម្មភាពរបស់ចៅក្រមសាលាដំបូង មិនត្រូវបានអនុញ្ញាតដោយច្បាប់ឡើយ ដូច្នេះសកម្មភាពនេះគឺមោឃៈ"[41]។ តុលាការបានសម្រេចថា៖

> សាលក្រមមោឃៈ គឺជាមោឃភាព ចាប់តាំងពីដើមដំបូង ហើយមិនអាចទទួលបានផលវិបាកណាមួយនៃសាលក្រមដែលមានសុពលភាពឡើយ។ សាលក្រមបែបនេះមិនទទួលបានការគោរពអ្វីឡើយ ព្រោះសាលក្រមនេះមិនមានអានុភាព មិនធ្វើឲ្យប៉ះពាល់ ឬបង្កើតសិទ្ធិតាមផ្លូវច្បាប់អ្វីទេ[42]។

២៣. នៅក្នុងរឿងក្ដី *រដ្ឋ តទល់នឹង Simpkins* តុលាការកំពូលរដ្ឋ Ohio បានញែកដាច់ពីគ្នារវាង កិច្ចតុលាការដែលអាចមោឃៈ ដែលផ្អែកលើកំហុសអង្គច្បាប់ និងកិច្ចតុលាការដែលខុសច្បាប់ទាំងស្រុង ដែលចាំបាច់ត្រូវធ្វើមោឃភាព៖

> នៅក្នុងកាលៈទេសៈ ដែលចៅក្រមមិនពិចារណាថាតើច្បាប់បង្គាប់បញ្ជាអ្វីឲ្យច្បាស់លាស់នោះ ដូចជានៅពេលដែលចៅក្រមមិនបានដាក់ទណ្ឌកម្ម ដែលមិនមានលក្ខណៈឆន្ទានុសិទ្ធិ ដែលតម្រូវដោយលក្ខន្តិកៈផ្ដន្ទាទោស ចៅក្រមនោះបំពេញកិច្ចដោយមិនមានសិទ្ធិអំណាច។ កិច្ចបែបនេះមិនត្រឹមតែជាកំហុសប៉ុណ្ណោះទេ តែធ្វើឲ្យការផ្ដន្ទាទោសអាចមោឃភាពបាន ប៉ុន្តែមិនមោឃៈទេ។ ប្រសិនបើចៅក្រមផ្ដន្ទាទោស ដោយមិនមានការអនុញ្ញាតតាមច្បាប់ ការផ្ដន្ទាទោសនោះគឺជាការខុសច្បាប់។ "ប្រសិនបើកិច្ចមួយខុសច្បាប់ កិច្ចនោះមិនមែនជា

---

កំណត់ដោយសាលាដំបូងគឺមោឃៈ។ "អានុភាពនៃការសម្រេចថា សាលក្រមមួយមោឃៈ ត្រូវបានកំណត់យ៉ាងច្បាស់លាស់ហាក់ដូចជាថា កិច្ចដំណើរការនីតិវិធីបែបនេះមិនដែលបានកើតមាន។ សាលក្រមជាមោឃភាព ហើយភាគីស្ថិតក្នុងស្ថានភាពដដែល ដូចមិនមានសាលក្រម"។ *សូមមើលផងដែរ* *Ex parte Seidel*, 39 S.W.3d 221, 225 (Tex. Crim. App. 2001)។

[40] *Ex parte Seidel*, 39 S.W.3d 221, 225 (Tex. Crim. App. 2001)។

[41] *ដូចជើងទំព័រខាងលើ*។

[42] *ដូចជើងទំព័រខាងលើ* ដកស្រង់ *Ex parte Spaulding*, 687 S.W.2d 741, 745 (Teague, J., concurring)។

កំហុស ឬអាចមោឃភាពបានទេ ប៉ុន្តែកិច្ចនោះគឺខុសច្បាប់ទាំងស្រុង និងមោឃៈ"[43]។

២៤. តុលាការកំពូលនៃចក្រភពអង់គ្លេស នាពេលថ្មីៗនេះបានតម្កល់គោលការណ៍មួយនេះ នៅក្នុងរឿងក្តី *R v. Miller* នៅក្នុងបរិបទនៃការផ្តល់យោបល់ដែលខុសច្បាប់ដោយនាយករដ្ឋមន្ត្រី ថ្វាយព្រះមហាក្សត្រថា គួរពន្យាពេលរដ្ឋសភា៖

> នេះមានន័យថា យោបល់នេះ គឺមោឃៈ និងមិនមានអានុភាព [...]។ វានាំទៅដល់ការបញ្ជានៅក្នុងក្រុមប្រឹក្សា ដែលធ្វើឡើងដោយផ្អែកលើយោបល់ខុសច្បាប់ ប្រហែលទៅជាខុសច្បាប់ មោឃៈ និងមិនមានអានុភាព ដែលគួរត្រូវបានបដិសេធចោល។ ចំណុចនេះនាំទៅដល់ការពន្យារពេលជាក់ស្តែង ដែលហាក់ដូចជាស្នងការដើរចូលទៅក្នុងសភា ដោយមានតែក្រដាសសទទេ។ ចំណុចនេះក៏ខុសច្បាប់ មោឃៈ និងមិនមានអានុភាពដែរ[44]។

២៥. យុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិបានទទួលស្គាល់ថា កិច្ច ឬដីកាសម្រេចខុសច្បាប់ ដូចជា កិច្ច ឬដីកាសម្រេច ដែលបំពានទៅលើនីតិវិធី ឬច្បាប់ជាធរមាន គឺមោឃៈ ហើយមិនមានអានុភាពគតិយុត្តិទេ។ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR ក្នុងរឿងក្តី *Ntuyahaga* បានសម្រេចថា ឯកសារស្តីពី "ការប្រព្រឹត្តិដោយសុវត្ថិភាព" របស់មន្ត្រីចុះបញ្ជី ដែលបានប្រគល់ជូនទៅចុងចោទ នៅពេលដែលគាត់ត្រូវបានដោះលែង គឺ "មោឃៈ" ដោយសារតែ "មិនមានបទប្បញ្ញត្តិនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ ឬរបស់លក្ខន្តិកៈ និងវិធាននីតិវិធី និងភស្តុតាង ឬលិខិតុបករណ៍ណាមួយ ដែលចេញដោយអង្គជំនុំជម្រះសាលាដំបូង ផ្តល់សិទ្ធិអំណាចដល់មន្ត្រីចុះបញ្ជី ឱ្យចេញឯកសារដែលមានចំណងជើងថា "ការប្រព្រឹត្តិដោយសុវត្ថិភាព"[45]។ អង្គ

---

[43] *State តទល់នឹង Simpkins*, 884 N.E.2d 568, 575 (Ohio ឆ្នាំ ២០០៨) (អក្សរទ្រេតគូសបញ្ជាក់បន្ថែមលើឯកសារដើម) (ការដកស្រង់ផ្ទៃក្នុង ត្រូវបានលុបចោល)។

[44] *R (on the application of Miller) (Appellant) តទល់នឹង The Prime Minister (Respondent) Cherry* និងអ្នកដទៃទៀត *others (Respondents) តទល់នឹង Advocate General for Scotland (Appellant) (Scotland)*, [2019] UKSC 41, កថាខណ្ឌ ៦៩។*សូមមើលផងដែរ R (on the application of UNISON) (Appellant) តទល់នឹង Lord Chancellor (Respondent)*, [2017] UKSC 51, កថាខណ្ឌ ១១៩៖ "ដីកាបង្គាប់ឱ្យបង់ថ្លៃ គឺខុសច្បាប់ទាំងតាមច្បាប់ជាតិ និងច្បាប់សហភាពអឺរ៉ុប ដោយសារតែដីកានេះមានអានុភាព រារាំងការទទួលបានយុត្តិធម៌។ ដោយសារតែដីកានេះមានអានុភាពភ្លាមៗ បន្ទាប់ពីចេញរួច ដូច្នេះដីកានេះខុសច្បាប់តាំងពីដំបូង ហើយចាំបាច់ត្រូវបដិសេធចោល"។

[45] អង្គជំនុំជម្រះសាលាដំបូង ១ នៃតុលាការ ICTR *រដ្ឋអាជ្ញា តទល់នឹង Ntuyahaga* (ICTR-98-40-T) "ការប្រកាសស្តីពីចំណុចច្បាប់" ថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៩៩ កថាខណ្ឌ ១, ៤, និង ១៧។ មន្ត្រីចុះបញ្ជីបានចេញឯកសារ ដែលមានចំណង

ជំនុំជម្រះសាលាដំបូង "ដឹងច្បាស់អំពីភាពចាំបាច់សម្រាប់តុលាការក្នុងការធានាអំពីការគោរព និងប្រតិបត្តិតាមច្បាប់"[46]។

២៦. អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY នៅក្នុងរឿងក្តី *Kupreškić និងអ្នកដទៃទៀត* បានសម្រេចថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទទួលយកសក្ខីកម្មពីសាក្សី មេធាវីការពារក្តី គឺ "មោឃៈ" ដោយមិនបានគោរពតាមលក្ខខណ្ឌតម្រូវនៃលក្ខន្តិកៈ និងវិធាននីតិវិធី និងភស្តុតាងរបស់តុលាការ ICTY[47]។ ចៅក្រមប្រធាននៃអង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីថា ចៅក្រមអង្គជំនុំជម្រះសាលាដំបូងមួយរូបមានជំងឺ ហើយប្រហែលជាមិនអាចចូលរួមក្នុងសវនាការពេញមួយសប្តាហ៍[48]។ បន្ទាប់មក ចៅក្រមប្រធានបានធ្វើសេចក្តីសម្រេចដោយផ្ទាល់មាត់ថា វិធាន ៧១ នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY អាចអនុវត្តបាន ហើយការទទួលយកសក្ខីកម្មពីសាក្សីមេធាវីការពារក្តី ត្រូវបានធ្វើឡើងដោយមានចៅក្រមតែពីររូប ដែលមានវត្តមានជាមន្ត្រីប្រធាន[49]។ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ គាំទ្រដល់ការសម្រេចដោយផ្ទាល់មាត់នៅថ្ងៃបន្ទាប់មក[50]។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា "លក្ខខណ្ឌតម្រូវក្នុងវិធាន ៧១ ដែលថា ដីកាបង្គាប់ឲ្យទទួលយកសក្ខីកម្ម អាចត្រូវបានធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូងតែមួយប៉ុណ្ណោះនោះ មិនត្រូវបានបំពេញឡើយ" ដោយសារតែមាត្រា ១២ នៃលក្ខន្តិកៈតុលាការ ICTY ចែងថា អង្គជំនុំជម្រះសាលាដំបូងត្រូវមាន

---

ដឹងថា "ការប្រព្រឹត្តិដោយសុវត្ថិភាព" ដោយស្នើដល់រដ្ឋជាសមាជិកអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ និងភាគីពាក់ព័ន្ធផ្សេងទៀត អនុញ្ញាតផ្តល់ដល់ចុងចោទនូវកិច្ចសហប្រតិបត្តិការដែលចាំបាច់នានា ដើម្បីឲ្យគាត់អាច "ធ្វើដំណើរដោយសេរីនៅក្នុងប្រទេស ឬឆ្លងកាត់ប្រទេសនានា ដោយគ្មានការរារាំង ឬហាមឃាត់ រហូតទៅដល់ទីដៅចុងក្រោយរបស់គាត់"។ មេធាវីការពារក្តីព្យាយាមស្នើសុំឯកសារច្បាប់ដើមនៃសេចក្តីសម្រេចនេះ ប៉ុន្តែសេចក្តីសម្រេចនេះក្នុងពេលបច្ចុប្បន្នស្ថិតក្រោមការត្រួតពិនិត្យគតិយុត្តិដោយតុលាការ ICTR (MICT) ដើម្បីសម្រេចលើការចាត់ប្រភេទគតិយុត្តិ ហើយមិនអាចផ្តល់ជូនជាសាធារណៈឡើយ។

[46] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១៧។

[47] អង្គជំនុំជម្រះតុលាការកំពូល តុលាការICTY *រដ្ឋអាជ្ញា តទល់នឹង Kupreškić និងអ្នកដទៃទៀត* (IT-95-16-AR73.3), "សាលដីកាលើបណ្តឹងឧទ្ធរណ៍ របស់ Dragan Papić ប្រឆាំងសេចក្តីសម្រេចបន្តនីតិវិធី ដោយការទទួលយកសក្ខីកម្ម" ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ ១៤។

[48] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៥។

[49] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៦ និង៧។

[50] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៧។

ចៅក្រមចំនួនបីរូប[51]។ អង្គជំនុំជម្រះតុលាការកំពូលយល់ថា ការគាំទ្រជាលាយលក្ខណ៍អក្សររបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើសេចក្ដីសម្រេចផ្ទាល់មាត់ "មិនអាចជួសជុល *ដោយខ្លួនឯង* (*ipso facto*) ចំពោះភាពខុសច្បាប់នេះឡើយ"[52]។

២៧. ការបកស្រាយដោយត្រឹមត្រូវចំពោះវិធាន ៦៧(២) ដោយពិចារណាទៅលើស្ថានភាពនៃវិធាននេះ នៅក្នុងក្របខណ្ឌច្បាប់ អ.វ.ត.ក រួមទាំងបរិបទនៃនីតិវិធីធ្វើមោឃភាព នៅក្នុងវិធាន ៧៦ នៃវិធានផ្ទៃក្នុង និងគោលការណ៍ និងគោលបំណងជាមូលដ្ឋានសំខាន់សម្រាប់ការធ្វើមោឃភាព មុនពេលជំនុំជម្រះ តម្រូវថា អានុភាពនៃការសម្រេចជាឯកច្ឆ័ន្ទរបស់អង្គបុរេជំនុំជម្រះ នៅក្នុងសំណុំរឿង ០០៤/២ គឺថា ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវមោឃៈ។ ចំណុចនេះត្រូវបានគាំទ្របន្ថែមទៀតដោយនីតិវិធីព្រហ្មទណ្ឌបារាំងនិងកម្ពុជា និងទស្សនៈនៃ "មោឃភាព" ដែលមាននៅក្នុងយុត្តាធិការជាតិ និងអន្តរជាតិ។ ការសម្រេចជាឯកច្ឆ័ន្ទរបស់អង្គបុរេជំនុំជម្រះទាំងស្រុងលើកលែងតែឈ្មោះនោះ គឺថា ការសម្រេចអំពីវិការៈនីតិវិធី[53] ដែលត្រូវមានផលវិបាក

---

[51] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១៤។

[52] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១៤៖ "នៅពេលដែលលក្ខន្តិកៈ ឬវិធានចែងកំណត់ថា បញ្ហាមួយត្រូវសម្រេចដោយអង្គជំនុំជម្រះសាលាដំបូង ចៅក្រមអាសនៈពីររូប មិនអាចបំពេញកិច្ចបានទេ ក្នុងនាមអង្គជំនុំជម្រះសាលាដំបូង លើកលែងតែក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូង បានទទួលការអនុញ្ញាតសិទ្ធិដោយចៅក្រមប្រធាន។ ប៉ុន្តែ ការអនុញ្ញាតសិទ្ធិនេះ អាចផ្ដល់តែក្នុងករណីបញ្ហាធម្មតាៗប៉ុណ្ណោះ ស្របទៅតាមអនុវិធាន ១៥(ង)។ ក្នុងករណីបច្ចុប្បន្ន ចៅក្រមប្រធានមិនបានផ្ដល់ការអនុញ្ញាតសិទ្ធិ ហើយក្នុងករណីណាក៏ដោយ ការធ្វើការសម្រេចបន្តនីតិវិធី តាមរយៈការទទួលយកសក្ខីកម្ម ពាក់ព័ន្ធនឹងការត្រួតពិនិត្យលើសាក្សីផ្ដល់ភស្តុតាងអង្គហេតុ ទាក់ទងនឹងបទចោទជាក់លាក់ ដែលបានធ្វើឡើងប្រឆាំងជនជាប់ចោទ មានអានុភាពដោយផ្ទាល់ចំពោះការសម្រេចលើពិរុទ្ធភាព ឬភាពគ្មានទោសរបស់ជនជាប់ចោទ ដែលតាមមតិរបស់អង្គជំនុំជម្រះតុលាការកំពូល មិនអាចចាត់ទុកថាជា "បញ្ហាធម្មតា" ទៅតាមអត្ថន័យនៃអនុវិធាន ១៥(ង) ឡើយ" (អក្សរទ្រេតគូសបញ្ជាក់បន្ថែមលើឯកសារដើម)។

[53] វិធាន ៧៦(៥) នៃវិធានផ្ទៃក្នុងចែងថា កិច្ចស៊ើបសួរដែលមានវិការៈ ត្រូវ "មោឃៈ" ហើយឯកសារដែលពាក់ព័ន្ធត្រូវ "ដកចេញពីសំណុំរឿង និងតម្កល់ទុកដោយក្រឡាបញ្ជីអង្គបុរេជំនុំជម្រះ"។ បន្ទាប់ពីការធ្វើមោឃភាព ឬការលុបចោលនោះ អង្គបុរេជំនុំជម្រះត្រូវបញ្ជូនសំណុំរឿងត្រឡប់ទៅឱ្យសហចៅក្រមស៊ើបអង្កេតវិញ"។ មានការលើកឡើងដដែលៗថា សូម្បីតែសហចៅក្រមស៊ើបអង្កេតក៏បានដឹងថា ការចេញដីកាដំណោះស្រាយ ដែលដាច់ពីគ្នាហើយផ្ទុយគ្នា គឺខុសច្បាប់ ហើយពួកគាត់បានដឹងយ៉ាងច្បាស់ថា ការចេញដីកាដំណោះស្រាយ ដែលដាច់ពីគ្នាហើយផ្ទុយគ្នា នឹងមិនអាចគេចផុតពីការត្រួតពិនិត្យវិនិច្ឆ័យរបស់អង្គបុរេជំនុំជម្រះនៅដំណាក់កាលបណ្ដឹងឧទ្ធរណ៍ក្ដី។ សេចក្ដីពិចារណា សំណុំរឿង ០០៤/២, កថាខណ្ឌ ១២៣ អង្គបុរេជំនុំជម្រះកត់សម្គាល់ "ការប្រកាសយ៉ាងច្បាស់ដោយសហចៅក្រមស៊ើបអង្កេត [...] ថា ពួកគាត់បានឯកភាពគ្នាលើការចេញដោយខុសច្បាប់នូវដីកាដំណោះស្រាយដាច់ពីគ្នាហើយផ្ទុយគ្នានេះ"។ អង្គបុរេជំនុំជម្រះបានឯកភាពជាឯកច្ឆ័ន្ទថា "ការអនុវត្តដោយខុសឆ្គងរបស់

នីតិវិធីដូចគ្នា ដូចមានចែងក្នុងវិធាន ៧៦(៥) នៃវិធានផ្ទៃក្នុង ស្ដីពី "មោឃភាព" "ការលុបចោល"[54]។ ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលមានវិការៈនីតិវិធី

---

សហចៅក្រមស៊ើបអង្កេត នៅក្នុងករណីនេះ បង្កគ្រោះថ្នាក់ដល់ប្រព័ន្ធតតិយុត្តិទាំងមូល ដែលគាំទ្រដោយរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ។ គួរឲ្យភ្ញាក់ផ្អើល ចៅក្រមស៊ើបអង្កេតបាន "ដឹងអំពីបញ្ហា" ដែលអាចកើតឡើងដោយសារតែដីកាដំណោះស្រាយដែលដាច់ពីគ្នា ជាពិសេសនៅដំណាក់កាលបណ្ដឹងឧទ្ធរណ៍នោះ [...]"។

[54] ដូចដែលអង្គបុរេជំនុំជម្រះបានសម្រេចជាឯកច្ឆ័ន្ទ "មិនដែលមានទាល់តែសោះ នៅក្នុងប្រវត្តិសាស្ត្រជាតិ ឬប្រព័ន្ធច្បាប់អន្តរជាតិ ដែលសំណុំរឿងព្រហ្មទណ្ឌមួយ មានលក្ខណៈប្រហាក់ប្រហែលនឹងការចេញសេចក្ដីសម្រេចពីរដែលផ្ទុយគ្នា ក្នុងពេលតែមួយ ដោយអង្គភាពតុលាការតែមួយនោះ" សេចក្ដីពិចារណា សំណុំរឿង ០០៤/២ កថាខណ្ឌ ១២៤។ ចាំបាច់ត្រូវមានការកត់សម្គាល់បន្តថា នីតិវិធីព្រហ្មទណ្ឌកម្ពុជា និងវិធាននីតិវិធីដែលបានកំណត់នៅកម្រិតអន្តរជាតិ មិនអាចឆ្លើយតបចំពោះផលវិបាកនីតិវិធីនៃដីកាដំណោះស្រាយផ្ទុយគ្នា ដែលចេញដោយខុសច្បាប់ឡើយ។ ប៉ុន្តែ វិធាន ២ និងវិធាន ២១ នៃវិធានផ្ទៃក្នុង ចែងពីគោលការណ៍ណែនាំក្នុងការបកស្រាយថា ច្បាប់នីតិវិធីព្រហ្មទណ្ឌដែលនៅជាធរមាន ចាំបាច់ត្រូវបកស្រាយ ក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនត្រូវចោទ។ *សូមមើល* កិច្ចព្រមព្រៀងស្ដីពីការបង្កើត អ.វ.ត.ក, មាត្រា ១២(១)។ ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក មាត្រា ៣៣ ថ្មី, វិធាន ២ វិធាន ២១ នៃវិធានផ្ទៃក្នុង។ មធ្យោបាយតែមួយក្នុងការការពារផលប្រយោជន៍លោក យឹម ទិត្យ គឺត្រូវបំពេញចន្លោះប្រហោង នៅក្នុងវិធានផ្ទៃក្នុង តាមរយៈការអនុវត្តបទប្បញ្ញតិតាមសទិសន័យ "ប្រសិនបើទទួលស្គាល់ពីអត្ថិភាពនៃចន្លោះប្រហោង តុលាការមានភារកិច្ចបំពេញបន្ថែមចន្លោះប្រហោងនេះ តាមរយៈការប្រើប្រាស់បទប្បញ្ញត្តិលក្ខន្តិកៈ ដែលគ្រប់គ្រងលើបញ្ហា ឬរឿងក្ដីប្រហាក់ប្រហែលគ្នានោះ" [...] "ពេលខ្លះ លក្ខន្តិកៈនឹងអះអាងថាពិនិត្យទៅលើប្រធានបទមួយយ៉ាងលម្អិត ប៉ុន្តែ "រឿងក្ដីដែលមិនអាចបង្ហាញ" នឹងកើតឡើង។ នៅទីនេះ តុលាការអាចពិនិត្យរឿងក្ដីនេះ ដោយសទិសន័យ ទៅតាមវិធីដែលរឿងក្ដី "ជាក់ស្ដែង" ត្រូវបានពិនិត្យ នៅក្នុងលក្ខន្តិកៈតែមួយ" Koszowski, M., "សំអាងហេតុបែបសទិសន័យ ក្នុងច្បាប់លក្ខន្តិកៈ" (ឆ្នាំ ២០១៧) *Journal Forensic Research* (8) 1, ទំព័រ ២ ដកស្រង់ Wróblewski, J., "ការបកស្រាយលក្ខន្តិកៈ នៅក្នុងប្រទេសប៉ូឡូញ" ក្នុងការបកស្រាយលក្ខន្តិកៈ៖ ការសិក្សាប្រៀបធៀប Ashgate/Dartmouth, Aldershot ឆ្នាំ ១៩៩១ ទំព័រ ២៥៧ ដល់៣០៩ និង Summers, R., "ការបកស្រាយលក្ខន្តិកៈ នៅក្នុងសហរដ្ឋអាមេរិក" ក្នុងការបកស្រាយលក្ខន្តិកៈ៖ ការសិក្សាប្រៀបធៀប Ashgate/Dartmouth Aldershot ឆ្នាំ ១៩៩១ ទំព័រ ៤០៧ ដល់៤៥៩។ *សូមមើលផងដែរ* Koszowski, M. "វិសាលភាពនៃការអនុវត្ត សំអាងហេតុបែបសទិសន័យ នៅក្នុងច្បាប់លក្ខន្តិកៈ" (ឆ្នាំ ២០១៧) *American International Journal of Contemporary Research* (7) 16, ទំព័រ ១៧ និង ១៩៖ "គម្លាតតតិយុត្តិ កើតឡើងនៅពេលណា ដែលមិនមានវិធានលក្ខន្តិកៈ ដែលអាចអនុវត្តបានចំពោះសំណុំរឿងនៅចំពោះមុខ ទោះបីជាមានសារៈសំខាន់សម្រាប់សង្គម ដែលត្រូវមានវិធានបែបនេះ និងមានចែងសម្រាប់រឿងក្ដីចំពោះមុខ[...]។ ការបំពេញចន្លោះប្រហោងនេះ ដោយងាកទៅរកសំអាងហេតុបែបសទិសន័យ ជាគោលការណ៍រួមមានការស្វែងរកវិធានលក្ខន្តិកៈ ដែលអនុវត្តចំពោះរឿងក្ដី ដែលមានភាពប្រហាក់ប្រហែល ចំពោះសំណុំរឿងបច្ចុប្បន្ន ហើយបន្ទាប់មក ទោះបីជារឿងក្ដីនោះ មិនស្ថិតក្រោមវិសាលភាពវិធាននោះក្ដី ក៏អនុវត្តវិធានដែលបានជ្រើសរើសនោះ ចំពោះរឿងក្ដីបច្ចុប្បន្ន [...]។ ការបំពេញចន្លោះប្រហោងក្រៅផ្លូវច្បាប់ ដោយសទិសន័យ ក៏មានមូលដ្ឋានផងដែរនៅក្នុងការស្វែងរក ទាំងក្នុងការអនុវត្តជាក់ស្ដែង និងក្នុងទ្រឹស្ដីច្បាប់ នូវភាពសមស្របគ្នា និងភាពពេញលេញនៃប្រព័ន្ធច្បាប់"។ (ការដកស្រង់ផ្ទៃក្នុង ត្រូវបានលុបចោល) *សូមមើលផងដែរ* Peczenik, A., 'Analogia Legis.

ចាំបាច់ត្រូវលុបចេញពីសំណុំរឿង ហើយមិនមានអានុភាពគតិយុត្តិអ្វីឡើយ[55]។

## III. ឧឡឹករណ៍បណ្តឹងឧទ្ធរណ៍ទាំងអស់លើអង្គសេចក្តីនៃដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ នាពេលនេះមិនមានភាពពាក់ព័ន្ធឡើយ ជាមួយនឹងកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន

២៨. ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កម្រិតត្រឹមមូលដ្ឋានដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដោយមិនលើកឡើងអំពីបញ្ហា ដែលមិនទាក់ទងនឹងអង្គសេចក្តីនៃដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិឡើយ។ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា លោក យឹម ទិត្យ (១) មិនបានបង្ហាញអំពីកំហុសអង្គច្បាប់ ដែលអាចពិនិត្យឡើងវិញ ឬការបំពានឆន្ទានុសិទ្ធិនៅក្នុងដំណើរការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងការសម្រេចចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយផ្អែកលើការអះអាងរបស់ យឹម ទិត្យ ដែលថា

---

Analogy from Statutes in Continental Law,' in Hubien, H. [Ed] *សំអាងហេតុគតិយុត្តិ កិច្ចដំណើរការនីតិវិធី នៃសមាជពិភពលោក សម្រាប់ទស្សនវិជ្ជាច្បាប់ និងសង្គម* 329, Brussels 1971, ទំព័រ ៣៣២ ដកស្រង់ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ៤ "សទិសន័យគឺជាទឡ្ហីករណ៍អត្ថាធិប្បាយ [...] ភ្ជាប់ជាមួយគោលការណ៍យុត្តិធម៌ដូចតទៅ គោលដៅដែលប្រហែលគ្នាខ្លាំង គួរត្រូវបានពិចារណាក្នុងលក្ខណៈប្រហាក់ប្រហែលគ្នា។ ទឡ្ហីករណ៍អត្ថាធិប្បាយ មិនអាចជៀសផុតបានពីការពិចារណាផ្លូវច្បាប់ឡើយ ដោយសារតែចៅក្រមមានកាតព្វកិច្ចសម្រេចរឿងក្តីមួយ បើទោះបីជាច្បាប់មានភាពមិនច្បាស់លាស់ (ឧទាហរណ៍ Code Napoléon, § 4, prohibition of *denegatio justitae*)។ Imre Zajte បានរៀបរាប់ពីដំណើរការនៃសំអាងហេតុលក្ខន្តិកៈសទិសន័យ ដូចតទៅ៖ "ប្រភេទទីមួយនៃសំអាងហេតុ ដោយសទិសន័យ ចាប់ផ្តើមពីចំណុចដំបូង វិធានត្រូវបានរៀបចំឡើងដោយច្បាប់ ឬលក្ខន្តិកៈជាលាយលក្ខណ៍អក្សរ។ ជាដំបូង ដំណើរការរួមមានការស្វែងរកអ្វីដែលបង្កើតបានជាធាតុផ្សំចម្បងនៃវិធាននោះ និងដើម្បីឈានដល់ចំណុចចុងក្រោយ វិធានត្រូវបានបំបែកចេញនូវធាតុផ្សំបន្ទាប់បន្សំទាំងអស់ ដូច្នេះវិធានត្រូវនៅសល់តែធាតុផ្សំសំខាន់ៗ ដែលដូច្នេះហើយនឹងអាចអនុវត្តចំពោះរឿងក្តីដែលខុសពីសម្មតិកម្ម ដែលផ្តល់ឱ្យដោយលក្ខន្តិកៈ និងជាពិសេសជាក់លាក់នោះ ចំពោះធាតុផ្សំបន្ទាប់បន្សំរបស់វា" Zajtay, I., "សំអាងហេតុដោយសទិសន័យ ជាវិធីសាស្ត្រមួយនៃការបកស្រាយច្បាប់" (ឆ្នាំ ១៩៨០)។*The Comparative and International Journal of Southern Africa* (13) 324, ទំព័រ ៣២៦។

[55] អង្គបុរេជំនុំជម្រះបង្គាប់ "ការលុបចោល និងដកចេញ" ផ្នែកដែលមានវិការៈនីតិវិធី នៃកិច្ចស៊ើបសួរ ចេញពីសំណុំរឿងនៅក្នុង *សាលដីកាលើសំណើរបស់ យឹម ទិត្យ សុំធ្វើមោឃភាពឯកសារស៊ើបអង្កេត ដែលធ្វើឡើងដោយ Paolo STOCCHI* ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧ ឯកសារ D351/1/4 កថាខណ្ឌ ៣៦ និង ទំព័រ ១៧។

សិទ្ធិជាសារវ័ន្តរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ត្រូវបានរំលោភបំពាន[56] (២) ខកខានក្នុងការបង្ហាញកំហុសអង្គច្បាប់ ដែលអាចពិនិត្យមើលឡើងវិញបាន អំពីភាពគ្រប់គ្រាន់នៃការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ" ដោយសារតែ "ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កំណត់ពីធាតុផ្សំជាលក្ខខណ្ឌស្របតាមវិធាន ៦៧(២)"[57] (៣) "ខកខានមិនបានបង្ហាញពីកំហុសដែលអាចពិនិត្យឡើងវិញបាន អំពីដែនកំណត់ផ្នែកអង្គហេតុ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ"[58] (៤) ខកខានមិនបានបង្ហាញពីកំហុស ដែលអាចពីនិត្យឡើងវិញបាន ដែលអះអាងថាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពឹងផ្អែកលើសហឧក្រិដ្ឋកម្មរួម"[59] និង (៥) "ខកខានមិនបានបង្ហាញពីកំហុស ដែលអាចពិនិត្យឡើងវិញបាន ក្នុងការសន្និដ្ឋានថា យឹម ទិត្យ ជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដូច្នេះហើយត្រូវស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក"[60]។

២៩. ដោយសារតែដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ គឺមោឃៈ (មិនមានអត្ថិភាព និងមិនមានអានុភាពគតិយុត្ត) រាល់ទឡ្ហីករណ៍បណ្តឹងឧទ្ធរណ៍លើអង្គសេចក្តីនៃដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានក្លាយជាគ្មានភាពពាក់ព័ន្ធចំពោះកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន។

៣០. មូលដ្ឋានបណ្តឹងឧទ្ធរណ៍ទាំងប្រាំ ដែលមេធាវីការពារក្តីបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងមូលដ្ឋានរងនៃបណ្តឹងឧទ្ធរណ៍ ដែលមានក្នុងនោះ លែងមានការពាក់ព័ន្ធជាមួយនឹងកិច្ចដំណើរការនីតិវិធីបច្ចុប្បន្នហើយ ដោយសារតែមូលដ្ឋានទាំងនេះ ពាក់ព័ន្ធតែជាមួយនឹងអង្គសេចក្តីនៃដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ មេធាវីការពារក្តីសូមលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (១) មានកំហុសផ្លូវអង្គច្បាប់ ដោយរំលោភបំពានទៅលើសិទ្ធិជាសារវ័ន្ត ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដោយការបំពេញកិច្ចស៊ើបសួរ និងចេញដីកាបញ្ជូនរឿងទៅ

---

[56] ចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ២៣។ *សូមមើលផងដែរ ដូចជើងទំព័រខាងលើ* កថាខណ្ឌ ២៤ ដល់ ៤៤។

[57] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៤៥។ *សូមមើលផងដែរ ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៤៦ ដល់៥៦។

[58] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៥៧ ដល់៦០។

[59] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៦១ ដល់៦៤។

[60] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៦៥ ដល់១៦៥។

ជំនុំជម្រះ ក្នុងកាលៈទេសៈដែលមិនអាចមានការជំនុំជម្រះប្រកបដោយយុត្តិធម៌[61] (២)មានកំហុសអង្គច្បាប់ដោយចេញដីកាដំណោះស្រាយដែលមោឃៈ ដោយសារវិការៈនីតិវិធី ព្រោះតែសហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានកំណត់ដោយត្រឹមត្រូវនូវអង្គច្បាប់ និងមិនបានយោងត្រឹមត្រូវទៅលើការវិភាគភស្តុតាងក្នុងការសម្រេចលើយុត្តាធិការបុគ្គលរបស់គាត់[62] (៣)មានកំហុសអង្គច្បាប់ដោយពង្រីកលើសវិសាលភាពអង្គហេតុនៃកិច្ចស៊ើបអង្កេត[63](៤)មានកំហុសអង្គច្បាប់ដោយប្រើប្រាស់ការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួម ធ្វើជាការពិចារណាពាក់ព័ន្ធក្នុងពេលវាយតម្លៃទៅលើយុត្តាធិការបុគ្គល[64] និង (៥)មានកំហុសអង្គច្បាប់ ក្នុងការសម្រេចថា លោក យឹម ទិត្យ ជា"អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដូច្នេះហើយត្រូវស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក[65]។

៣១. បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបានចាត់ទុកជាឥតបានការ ក្នុងន័យថា "មិនមានសារៈសំខាន់ជាក់ស្តែង"[66]។ "បណ្តឹងឧទ្ធរណ៍គួរ "ត្រូវបានបដិសេធចោលថាឥតបានការ នៅពេលដែលមានព្រឹត្តិការណ៍មួយ ដែលសាលាឧទ្ធរណ៍មិនបានផ្តល់ "ដំណោះស្រាយប្រកបដោយប្រសិទ្ធភាពណាមួយ" ដែលជាប្រយោជន៍ដល់ម្ចាស់បណ្តឹងឧទ្ធរណ៍"" ឬនៅពេលដែល "លែងមានអានុភាពដល់សិទ្ធិរបស់គូភាគីនៅក្នុងរឿងក្តី"[67]។ ជាលទ្ធផល ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ក៏ក្លាយជាឥតបានការ ហើយគួរត្រូវបានបដិសេធចោល ដោយសារតែចម្លើយតបនេះធ្វើឡើងតែចំពោះមូលដ្ឋានដែលបានលើកឡើងក្នុង

---

[61] បណ្តឹងឧទ្ធរណ៍ ចំពោះដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ២០ ដល់៥៥។

[62] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៥៦ ដល់៩៤។

[63] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៩៥ ដល់១០៣។

[64] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១០៤ ដល់១២០។

[65] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១២១ ដល់២៦៥។

[66] Garner, B., [Ed.] *Black's Law Dictionary*, 9th edition, ទំព័រ ១០៩៩។ *សូមមើលផងដែរ Stotts តទល់នឹង Community Unit Sch. Dist. No. 1*, 230 F.3d 989, 990 (7th Cir. 2000) (នៅពេលដែលសេចក្តីសម្រេចរបស់តុលាការ មិនមានអានុភាពជាក់ស្តែងទៅលើភាគី រឿងក្តីទៅជាអាសាឥតការ)។

[67] *Dorel Juvenile Group, Inc. តទល់នឹង DiMartinis*, 495 F.3d 500, 503 (7th Cir. 2007) *ដកស្រង់ Calderon តទល់នឹង Moore*, 518 U.S. 149, 150 (1996) និង ដកស្រង់ *Worldwide Street Preachers' Fellowship តទល់នឹង Peterson*, 388 F.3d 555, 558 (7th Cir. 2004)។ *សូមមើលផងដែរ Borowski តទល់នឹង Canada (Attorney General)* [1989] 1 SCR 342, 344: "បណ្តឹងឧទ្ធរណ៍នឹងអាសាឥតការ នៅពេលដែលសេចក្តីសម្រេចមិនមានអានុភាព ដោះស្រាយវិវាទខ្លះៗ ដែលបានប៉ះពាល់ ឬអាចនឹងប៉ះពាល់ដល់សិទ្ធិរបស់ភាគី"។

បណ្ដឹងឧទ្ធរណ៍ឥតបានការប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។

៣២. ចៅក្រមរបស់ អ.វ.ត.ក បានទទួលស្គាល់ពីស្ថានភាព ដែលសេចក្ដីសម្រេច ឬការដាក់សារណាមួយ ត្រូវបានចាត់ទុកថាជា "ឥតបានការ" ដោយសារតែលែងមានបញ្ហាជាក់ស្ដែងទៀតសម្រាប់ឱ្យតុលាការធ្វើការសម្រេច[68]។ និយាយឱ្យចំទៅ ចៅក្រមរបស់ អ.វ.ត.ក បានប្រកាសថា ចម្លើយ

---

[68] *សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេច លើសំណើសុំបំពេញកិច្ចស៊ើបសួរទាក់ទងនឹងអំពើហិង្សាផ្លូវភេទ នៅតុកលេខ៨ និងនៅក្នុងស្រុកបាកាន* ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ ឯកសារ D365/3/1/5, កថាខណ្ឌ ៣០ ដល់៣២។ *សូមមើលផងដែរ សេចក្ដីជូនដំណឹងពី សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទៅភាគីនានាស្ដីពីការចេញសាឡើងវិញ នូវដីកាសម្រេចដែលចៅក្រម Harmon បានសម្រេចនៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥ ឬបន្ទាប់ពីកាលបរិច្ឆេទនេះ* ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ D262 កថាខណ្ឌ ២ ដល់៤។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Bohlander សម្រេចថា សេចក្ដីសម្រេចដែលចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Harmon ក្រោយពេលដែលគាត់បញ្ចប់ការងារ មិនមានអានុភាព គតិយុត្តិ ដោយសារតែអាណត្តិការងារគាត់បានបញ្ចប់ នៅពេលដែលគាត់ចេញដីកាសម្រេចទាំងនោះ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Bohlander បានជូនដំណឹងដល់ភាគីនានាថា "ដីកាសម្រេចណាដែលអាចត្រូវប្ដឹងឧទ្ធរណ៍ នឹងក្លាយជាដីកាសម្រេចលែងមានសុពលភាព" នៅពេលដែលគាត់ចេញសារឡើងវិញនូវដីកាសម្រេចថ្មី។ សំណុំរឿង ០០៣ *សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Harmon អំពីការចោទប្រកាន់ប្រឆាំង មាស មុត* ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ D128.1/1/11 កថាខណ្ឌ ៦ ដល់៨។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Bohlander បានលុបចោលបទចោទដែលបានធ្វើឡើងក្នុងសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Harmon ដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យដោយកំបាំងមុខ និងជូនដំណឹងដល់ មាស មុតថា "ការចោទប្រកាន់ដែលមាន នៅក្នុងសេចក្ដីសម្រេចនេះ លែងមានសុពលភាព"។ នៅពេលដែល មាស មុត បានដាក់បណ្ដឹងឧទ្ធរណ៍ថ្មី ប្រឆាំងនឹងការចោទប្រកាន់របស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Bohlander អង្គបុរេជំនុំជម្រះសម្រេចថា បណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងការចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Bohlander លែងមានសុពលភាព ហើយគួរត្រូវបានបដិសេធចោល ដោយមិនចាំបាច់សម្រេចលើភាពអាចទទួលយកបាន ឬអង្គសេចក្ដីឡើយ"។ *ដីកាសម្រេចបន្ថែមលើសំណើបន្ទាន់សុំធ្វើការពីចម្ងាយ* ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ ឯកសារ D321/4 កថាខណ្ឌ ២ និង ៥ ដល់៧។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ប្រកាសថា*សំណើបន្ទាន់សុំធ្វើការពីចម្ងាយ* លែងមានសុពលភាព ដោយផ្អែកលើសំណើរបស់អង្គភាពគាំពារការការពារក្ដី នូវលក្ខខណ្ឌបំពេញការងារថ្មី សម្រាប់ទីប្រឹក្សាច្បាប់។ សំណុំរឿង ០០៤/១ *ដីកាសម្រេចលើសំណើបន្ទាន់ របស់អ្នកស្រី អ៊ឹម ចែម ស្នើសុំឱ្យបញ្ជូនសំណើសុំមោឃភាព ដីកាកោះហៅអ្នកស្រី និងសហមេធាវីការពារក្ដីគាត់ ទៅអង្គបុរេជំនុំជម្រះ* ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៤ ឯកសារ D207/1 កថាខណ្ឌ ៣៥ និង ៣៨។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ប្រកាសថា សំណើរបស់ អ៊ឹម ចែម សុំផ្អាកដីកាកោះហៅជនសង្ស័យ និងមេធាវីការពារក្ដី លែងមានសុពលភាព ដោយសារតែគាត់មិនបានបង្ហាញខ្លួន តាមកាលបរិច្ឆេទកំណត់ សម្រាប់ការបង្ហាញខ្លួនជាលើកដំបូង ដោយសារការជូនដំណឹងរបស់សហមេធាវីគាត់ថា គាត់នឹងមិនបង្ហាញខ្លួនដោយស្ម័គ្រចិត្តនៅ អ.វ.ត.ក និងការបដិសេធរបស់អង្គបុរេជំនុំជម្រះ ចំពោះសំណើសុំផ្អាករបស់គាត់។

តប និងការឆ្លើយតបក្លាយជាឥតបានការ ក្នុងករណីដែលចៅក្រមបដិសេធចំពោះសារណាជាមូលដ្ឋាន ឬមិនបានចាត់ទុកថាមានភាពចាំបាច់ក្នុងការស្តាប់ទឡ្ហីករណ៍បន្ថែមទៀត[69]។ ឧទាហរណ៍ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង០០២/០២ បានបដិសេធការដាក់ឯកសារដែលបានស្នើសុំឡើងដោយ នួន ជា នោះ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា សំណើសុំរបស់សហព្រះរាជអាជ្ញា នៅក្នុងចម្លើយតប គឺឥតបានការ "ដោយសារតែអង្គជំនុំជម្រះបានបដិសេធការដាក់ឯកសារលេខ ៨ ទើបសំណើសុំក្នុងចម្លើយតបរបស់សហព្រះរាជអាជ្ញា សុំដាក់ឯកសារបីទៅ

---

សំណុំរឿង ០០៤/២ *ដីកាសម្រេចលើសំណើរបស់ អោ អាន សុំការបញ្ជាក់បំភ្លឺ* ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៧ ឯកសារ D369 កថាខណ្ឌ ១១, ២០, ៣៨ និង ៣៩។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានប្រកាសថាសំណើររបស់ អោ អាន សុំការបញ្ជាក់បំភ្លឺ ថាតើសហព្រះរាជអាជ្ញា នឹងដាក់ដីកាសន្និដ្ឋានស្ថាពរដាច់ពីគ្នាដែរឬអត់ និងអានុភាពដែលការខ្វែងយោបល់គ្នា រវាងសហព្រះរាជអាជ្ញាមាន ចំពោះពេលវេលានៃដីកាសន្និដ្ឋានស្ថាពរ ដោយសារតែសហព្រះរាជអាជ្ញាទាំងពីរ បានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ពួកគេរួចហើយ។ បន្ថែមលើនេះ តុលាការព្រហ្មទណ្ឌអន្តរជាតិ បានប្រកាសថាការដាក់ឯកសារ និងសេចក្តីសម្រេច "លែងមានសុពលភាព" នៅពេលដែលលែងមានការជំទាស់ សម្រាប់តុលាការធ្វើការសម្រេច។ ចៅក្រមជាន់ខ្ពស់ អង្គជំនុំជម្រះតុលាការកំពូល នៃតុលាការ MICT ចៅក្រម Jean-Claude Antonetti, រដ្ឋអាជ្ញា *តទល់នឹង Karadžić* (MICT-13-55-A) "ដីកាសម្រេចលើញត្តិសុំប្តឹងជំទាស់ចៅក្រម Theodor Meron" ថ្ងៃទី២ ខែតុលា ឆ្នាំ២០១៨ ទំព័រ ២។ ចៅក្រម Meron សម្រេចដកខ្លួនចេញពីបណ្តឹងឧទ្ធរណ៍ក្នុងរឿងក្តី *Karadžić*, ធ្វើឱ្យញត្តិរបស់មេធាវីការពារក្តី សុំប្តឹងជំទាស់គាត់ ទៅជាលែងមានសុពលភាព។ ចៅក្រមប្រធាន MICT រដ្ឋអាជ្ញា *តទល់នឹង Nikolić* (MICT-14-65-ES), "ឯកសារកោសលប់ជាសាធារណៈ នៃដីកាសម្រេចចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៧ លើសំណើរបស់ Ratko Mladić សុំការអនុញ្ញាតឆ្លើយតប និងពិចារណាឡើងវិញ ឬជាជម្រើសមួយទៀត គឺវិញ្ញាបនកម្ម ឬប្តឹងជំទាស់" ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៨ កថាខណ្ឌ ២៨ ជើងទំព័រ ៥២ ("ដោយផ្អែកលើអង្គហេតុដែលថា ខ្ញុំបានអនុញ្ញាតតាមសំណើរបស់ Mladić សុំការពិចារណាឡើងវិញដោយផ្អែក ទើបខ្ញុំបដិសេធថាលែងមានសុពលភាព ចំពោះសំណើជាជម្រើសផ្សេងទៀតរបស់ Mladić សុំវិញ្ញាបនកម្មប្តឹងឧទ្ធរណ៍ សេចក្តីសម្រេចផ្តល់សិទ្ធិ ឬប្តឹងជំទាស់រូបខ្ញុំ")។ អង្គជំនុំជម្រះតុលាការកំពូល តុលាការ STL រដ្ឋអាជ្ញា *តទល់នឹង Ayyash និងអ្នកដទៃទៀត* (STL-11-01/PT/AC/AR90.2) *"សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី ប្រឆាំងដីកាសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូង លើការចោទពីរការៈក្នុងទម្រង់ជា ដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយមានកែប្រែ"* ថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៣ កថាខណ្ឌ ២៖ "ដោយសារតែដីកាបញ្ជូនរឿងទៅជំនុំជម្រះមុន បានទម្លាក់ចោលបាត់ទៅហើយ ទើបការជំទាស់ចំពោះដីកានេះលែងមានសុពលភាព។ ហេតុដូច្នេះយើងបដិសេធ បណ្តឹងឧទ្ធរណ៍នេះ"។

[69] សំណុំរឿង ០០២/០២ ប្រតិចារឹកសវនាការ អង្គជំនុំជម្រះសាលាដំបូង ថ្ងៃ ទី១៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ E1/484.1 នៅត្រង់ ERN 01385461 ជួរ ១២ ដល់១៤។ សំណុំរឿង ០០២/០១ *សេចក្តីសម្រេចលើសំណើរបស់ សហព្រះរាជអាជ្ញា ស្នើសុំបើកសវនាការលើបណ្តឹងឧទ្ធរណ៍ ពាក់ព័ន្ធនឹងវិសាលភាព នៃសវនាការសំណុំរឿង ០០២/០១ ឬស្នើសុំដាក់ចម្លើយតបរួម* ថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០១២ ឯកសារ E163/5/1/12 កថាខណ្ឌ ៣ និង៤។

ជាអាសាឥតការ"[70]។ នៅក្នុងឧទាហរណ៍មួយទៀត អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធសំណើរបស់សហព្រះរាជអាជ្ញា សុំបើកសវនាការជាសាធារណៈ ហើយបដិសេធសំណើជាជម្រើសមួយផ្សេងទៀត សុំដាក់ការឆ្លើយតបរួម ចំពោះចម្លើយតបរបស់មេធាវីការពារក្តី ចំពោះបណ្តឹងឧទ្ធរណ៍របស់ខ្លួន ដោយប្រកាសថា ឥតបានការ ដោយសារតែមិនមានភាពចាំបាច់ក្នុងការស្តាប់បន្ថែមទៀតចំពោះទឡ្ហីករណ៍លើបណ្តឹងឧទ្ធរណ៍[71]។

៣៣. តុលាការព្រហ្មទណ្ឌអន្តរជាតិក៏បានប្រកាសដូចគ្នាថាឥតបានការចំពោះសារណានៅក្នុងចម្លើយតបក្នុងករណីដែលខ្លួនបានបដិសេធសារណាជាមូលដ្ឋាន ឬមិនចាត់ទុកថាមានភាពចាំបាច់ក្នុងការស្តាប់ទឡ្ហីករណ៍បន្ថែមទៀត[72]។ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ក្នុងរឿងក្តី *Karadžić* បានបដិសេធថាឥតបានការចំពោះសំណើរបស់ជនជាប់ចោទ សុំពន្យារពេលសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល លើបណ្តឹងឧទ្ធរណ៍របស់ខ្លួន រហូតដល់ពេលដែលគាត់ទទួលបានភស្តុតាងបន្ថែមទៀត សម្រាប់ដាក់ជូន អនុលោមទៅតាម វិធាន ១១៥ នៃវិធានស្តីពីនីតិវិធី និងភស្តុតាង របស់តុលាការ ICTY និងសំណើរបស់រដ្ឋអាជ្ញាសុំអនុញ្ញាតដាក់ការឆ្លើយតបបន្ថែម ដោយពិចារណាថា ជនជាប់ចោទបានដាក់ញត្តិតាមវិធាន ១១៥ របស់គាត់ មុនពេលអង្គជំនុំជម្រះតុលាការកំពូល បានចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍[73]។ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ

---

[70] សំណុំរឿង ០០២/០២ ប្រតិចារឹកសវនាការ អង្គជំនុំជម្រះសាលាដំបូង ថ្ងៃ ទី១៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ E1/484.1 នៅត្រង់ ERN 01385461 ជួរ ១២ ដល់១៤។

[71] សំណុំរឿង ០០២/០១ *សេចក្តីសម្រេចលើសំណើរបស់ សហព្រះរាជអាជ្ញា ស្នើសុំបើកសវនាការលើបណ្តឹងឧទ្ធរណ៍ ពាក់ព័ន្ធនឹងវិសាលភាព នៃសវនាការសំណុំរឿង ០០២/០១ ឬស្នើសុំដាក់ចម្លើយតបរួម* ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១២ ឯកសារ E163/5/1/12 កថាខណ្ឌ ៣ និង៤។

[72] អង្គជំនុំជម្រះតុលាការកំពូល តុលការ ICTY រដ្ឋអាជ្ញា *តទល់នឹង Karadžić* (IT-95-5/18-AR73.4) *"សាលដីកាលើបណ្តឹងឧទ្ធរណ៍ របស់ Karadžić ប្រឆាំងដីកាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការចោទប្រកាន់ពីកិច្ចព្រមព្រៀង Holbrooke" ថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩* កថាខណ្ឌ ៥៦។ អង្គជំនុំជម្រះសាលាដំបូង ៤ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ រដ្ឋអាជ្ញា *តទល់នឹង Ntaganda* (ICC-01/04-02/06-2109) *"សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញា សុំដាក់បង្ហាញពាក់ព័ន្ធសាក្សី D-0017"* ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ កថាខណ្ឌ ៥ និង ទំព័រ ៩។

[73] *សូមមើល* អង្គជំនុំជម្រះតុលាការកំពូល នៃតុលាការ ICTY រដ្ឋអាជ្ញា *តទល់នឹង Karadžić* (IT-95-5/18-AR73.4) *"សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ Karadžić ប្រឆាំងដីកាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ពីការចោទប្រកាន់ពីកិច្ចព្រមព្រៀង Holbrooke" ថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩* កថាខណ្ឌ ៥៦៖ "ដោយពិចារណាថា ម្ចាស់បណ្តឹងឧទ្ធរណ៍បានដាក់ញត្តិតាមវិធាន១១៥របស់គាត់ នៅមុនពេលចេញដីកាសម្រេចបច្ចុប្បន្ននេះ អង្គជំនុំជម្រះតុលាការកំពូល សូមបដិសេធ

ព្រហ្មទណ្ឌអន្តរជាតិ ក្នុងរឿងក្តី *Ntaganda* បានប្រកាសថាឥតបានការចំពោះចម្លើយតបរបស់មេធាវីការពារក្តី ចំពោះសំណើរបស់រដ្ឋអាជ្ញា សុំការអនុញ្ញាតដាក់ការឆ្លើយតប ដោយអង្គជំនុំជម្រះសម្រេចថា "មិនមានប្រយោជន៍អ្វី ក្នុងការទទួលសារណាបន្ថែម ទៅលើបញ្ហាណាមួយក្នុងចំណោមបញ្ហាទាំងប្រាំ ដែលរដ្ឋអាជ្ញាបានបង្ហាញ ក្នុងសំណើសុំអនុញ្ញាតឆ្លើយតប" និងថា ហេតុដូច្នេះ ជាការមិនចាំបាច់ក្នុងការដោះស្រាយចំពោះចម្លើយតបរបស់មេធាវីការពារក្តី[74]។

៣៤. មិនមានទឡ្ហីករណ៍ផ្នែកអង្គច្បាប់បន្ថែមទៀតក្នុងការឆ្លើយតបចំពោះចម្លើយតប ដែលឥតបានការរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដោយសារតែសេចក្តីសម្រេចនៃបណ្តឹងឧទ្ធរណ៍ឥតបានការចំពោះដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនមានអានុភាពអ្វីឡើយ ដូច្នេះហើយត្រូវបដិសេធចោលភ្លាមៗ[75]។

## សេចក្តីសន្និដ្ឋាន

៣៥. អង្គបុរេជំនុំជម្រះបានប្រកាសរួចហើយអំពីភាពខុសច្បាប់នៃការចេញដីកាដំណោះស្រាយចំនួនពីរ ដូច្នេះ លទ្ធផលនៃបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹងការចេញដីកាដំណោះស្រាយពីរបានបញ្ចប់ដោយជៀសមិនផុតឡើយ។

៣៦. ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សំអាងលើ "កំហុសអង្គច្បាប់ធ្ងន់ធ្ងរ"[76] ដែលធ្វើឲ្យសេចក្តីសម្រេចគ្មានសុពលភាព[77]។ ការចេញដីកាដំណោះស្រាយ "រំលោភបំពាន

---

សំណើរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ក្នុងការពន្យាពេលសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល លើបណ្តឹងឧទ្ធរណ៍និងសំណើរបស់រដ្ឋអាជ្ញា សុំដាក់ការឆ្លើយតបបន្ថែម ដោយសារតែលែងមានសុពលភាព"។

[74] អង្គជំនុំជម្រះសាលាដំបូង ៤ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ រដ្ឋអាជ្ញា *តទល់នឹង* Ntaganda (ICC-01/04-02/06-2109) *"សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញា សុំដាក់បង្ហាញពាក់ព័ន្ធសាក្សី D-0017"* ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ កថាខណ្ឌ ៥ និងទំព័រ ៩។

[75] នៅក្នុងសំណុំរឿង ០០៤/២ អង្គបុរេជំនុំជម្រះបានប្រកាសថា អង្គជំនុំជម្រះមិនអាចស្វែងរកសម្លេងគាំទ្រភាគច្រើនលើសលប់តាមមាត្រា ៧(៤) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក តែចំពោះសម្លេងឆ្នោតវិជ្ជមានសម្រាប់ "សម្លេងគាំទ្រយ៉ាងតិចបួនសម្លេង សម្រាប់ការចេញសាលដីកា ផ្អែកលើសំអាងហេតុរួមគ្នា *លើអង្គសេចក្តីបានឡើយ*" សេចក្តីពិចារណា សំណុំរឿង ០០៤/២ កថាខណ្ឌ ១៦៩។

[76] សេចក្តីពិចារណា សំណុំរឿង ០០៤/២ កថាខណ្ឌ ៩៨ និង ៩៩។

ទៅលើមូលដ្ឋានផ្ទាល់នៃប្រព័ន្ធច្បាប់ អ.វ.ត.ក"[78]។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះត្រូវតែឆ្លើយតប ចំពោះសកម្មភាពហួសដែនសមត្ថកិច្ច (*ultra vires*) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដោយផ្តល់ការជួសជុលមួយក្នុងចំណោមការជួសជុលនានា ដែលបានស្នើសុំក្នុង*បណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងការចេញដីកាដំណោះស្រាយពីរ* គឺការបដិសេធទាំងស្រុងចំពោះដីកាដំណោះស្រាយ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលមានវិការៈ[79] បដិសេធដីកាដំណោះស្រាយ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលមានវិការៈ ហើយបង្វិលត្រឡប់សំណុំរឿង ទៅ សហចៅក្រមស៊ើបអង្កេត[80] ឬបដិសេធដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត អន្តរជាតិ ដែលមានវិការៈ ហើយធ្វើការវាយតម្លៃលើសំណុំរឿង ០០៤ ដោយអង្គជំនុំជម្រះផ្ទាល់ និងចេញដីកាដំណោះស្រាយផ្ទាល់របស់អង្គបុរេជំនុំជម្រះ[81]។ ការអនុវត្តផ្សេងពីនេះ ដោយបន្តកិច្ច

---

[77] *សូមមើល* សេចក្តីពិចារណា សំណុំរឿង ០០៤/២ កថាខណ្ឌ ៣០។ សំណុំរឿង ០០៤/១ *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ)* ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារD308/3/1/20 កថាខណ្ឌ ២២។

[78] សេចក្តីពិចារណា សំណុំរឿង ០០៤/២ កថាខណ្ឌ ១០២។

[79] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៨។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៥ ថ្មី វិធាន ២១(១)(ឃ) នៃ វិធានផ្ទៃក្នុង កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤(២)។

[80] វិធាន ៧៦(៥) នៃវិធានផ្ទៃក្នុង, រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣១ និង៣៨, ក្រមនីតិវិធីព្រហ្មទណ្ឌនៃ ព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៥១, ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៥ ថ្មី វិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុង, កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤(២)។ *សូមមើលផងដែរ* សំណុំរឿង ០០៤/១ *សេចក្តីពិចារណាលើ បណ្តឹងឧទ្ធរណ៍ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ)* ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារD308/3/1/20 កថាខណ្ឌ ២២។

[81] វិធាន ៧៩(១) នៃវិធានផ្ទៃក្នុង, រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៨, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រ កម្ពុជា មាត្រា ៣៥១, ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ៣៥ ថ្មី, វិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុង, កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤(២)។ *សូមមើលផងដែរ* សំណុំរឿង ០០១ *សាលដីកាលើបណ្តឹង ឧទ្ធរណ៍ ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច"* ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ D99/3/42 កថាខណ្ឌ ៤០។ សំណុំរឿង ០០៤/១ *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំង នឹងដីកាដំណោះស្រាយ (សំអាងហេតុ)* ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារD308/3/1/20 កថាខណ្ឌ ២២។ អង្គបុរេជំនុំ ជម្រះ "បំពេញតួនាទីជាសភាស៊ើបសួរ តាមក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា នៅក្នុង អ.វ.ត.ក" និងនៅពេល ទទួលបានបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ "វិធាន៧៩(១) នៃវិធានផ្ទៃក្នុងស្នើឡើងថា អង្គបុរេជំនុំជម្រះមានអំណាច

ដំណើរការនីតិវិធីផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលចេញដោយខុសច្បាប់ នឹងរំលោភបំពានដោយមិនអាចកែប្រែបាន ចំពោះសិទ្ធិជាមូលដ្ឋានរបស់លោក យឹម ទិត្យ ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌។

៣៧. អង្គបុរេជំនុំជម្រះ "ទទួលខុសត្រូវក្នុងការធានា នៅដំណាក់កាលស៊ើបសួរថា គោលការណ៍ជាសារវ័ន្តដែលជាមូលដ្ឋាននៃនីតិវិធីព្រហ្មទណ្ឌជាធរមាននៅចំពោះមុខ អ.វ.ត.ក ត្រូវបានគោរព"[82]។ សកម្មភាពដែលសមស្របបំផុតគឺថា អង្គបុរេជំនុំជម្រះត្រូវបិទបញ្ចប់ជាស្ថាពរនូវសំណុំរឿង០០៤ ដោយបដិសេធចោលដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលមានវិការៈ និងសំណុំរឿងប្រឆាំងលោក យឹម ទិត្យ ទាំងស្រុង។ ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលមានវិការៈនីតិវិធី និងខុសច្បាប់ គឺមោឃៈ ផ្អែកតាមវិធាន ៦៧(២) នៃវិធានផ្ទៃក្នុង។ ដោយសារតែមិនមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាព វិធាន ៧៧(១៣)(ខ) មិនអាចអនុវត្តបានទេ ហើយអង្គជំនុំជម្រះសាលាដំបូងមិនអាចទទួលវិនិច្ឆ័យសំណុំរឿង ០០៤ទេ[83]។ បច្ចុប្បន្ននេះ មិនមាននីតិវិធីជាធរមាននៅ អ.វ.ត.ក[84] និងមិនមាននីតិវិធីបែបនេះ ដែលអាចយកមកប្រើប្រាស់បាន ទោះជាក្នុងកាលៈទេសៈណាក្តី ដែលអាចអនុញ្ញាតឲ្យបញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលមោឃៈ និងខុសច្បាប់ ទៅអង្គជំនុំជម្រះសាលាដំបូងឡើយ។ ដូចដែលអង្គបុរេជំនុំជម្រះបានកត់សម្គាល់ មិនដែលធ្លាប់មាន "នៅក្នុងប្រវត្តិសាស្ត្រជាតិ ឬប្រព័ន្ធច្បាប់

---

ចេញដីកាដំណោះស្រាយថ្មីមួយ ឬចេញដីកាដំណោះស្រាយដែលបានកែប្រែរួច។ ដីកានេះនឹងយកមកធ្វើជាមូលដ្ឋាន នៃការជំនុំជម្រះ"។

[82] សេចក្តីពិចារណា សំណុំរឿង ០០៤/២ កថាខណ្ឌ ៥២។

[83] ប្រសិនបើអង្គបុរេជំនុំជម្រះ មិនអាចឈានដល់សេចក្តីសម្រេច ដោយសម្លេងភាគច្រើនលើសលប់ទេ អង្គជំនុំជម្រះសាលាដំបូងមិនអាចទទួលយកដោយផ្អែកលើ ដីកាដំណោះស្រាយដែលគ្មានសុពលភាព ដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែមួយរូបនោះឡើយ។ វិធាន ៧៩ នៃវិធានផ្ទៃក្នុង៖ "អង្គជំនុំជម្រះសាលាដំបូងទទួលបណ្តឹង ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ឬ តាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ"។

[84] សវនាការនៅ អ.វ.ត.ក ចាំបាច់ត្រូវប្រព្រឹត្តឡើង "ទៅតាមនីតិវិធីជាធរមាន"។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ៣៣ថ្មី។*សូមមើលផងដែរ* សេចក្តីពិចារណា សំណុំរឿង ០០៤/២ កថាខណ្ឌ ៩៥៖ "មាត្រា ២០ថ្មី ២៣ថ្មី ៣៣ថ្មី និង៣៧ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ក៏បានចែងយ៉ាងច្បាស់ថា ស្ថាប័នរបស់ អ.វ.ត.ក ត្រូវតែគោរពតាមនីតិវិធី ដែលនៅជាធរមានទាំងអស់។ អង្គជំនុំជម្រះសម្រេចថា បទប្បញ្ញត្តិទាំងអស់នេះ មានគោលដៅធានានូវនីត្យានុកូលភាព ភាពយុត្តិធម៌ និងប្រសិទ្ធភាពរបស់ កិច្ចដំណើរការនីតិវិធី អ.វ.ត.ក"។

អន្តរជាតិ ដែលសំណុំរឿងព្រហ្មទណ្ឌមួយ មានលក្ខណៈប្រហាក់ប្រហែលនឹង ការចេញសេចក្ដីសម្រេចពីរដែលផ្ទុយគ្នា ក្នុងពេលតែមួយដោយអង្គភាពតុលាការតែមួយនោះ”[85] ហើយក៏មិនដែលធ្លាប់មាន ការជំនុំជម្រះព្រហ្មទណ្ឌ ផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលមោឃៈ និងខុសច្បាប់ដែរ។

៣៨. ជាជម្រើសមួយទៀត ក្នុងករណីដែលអង្គបុរេជំនុំជម្រះមិនពិចារណាលើការបដិសេធដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលមានវិការៈ ទាំងស្រុងនោះ អង្គបុរេជំនុំជម្រះគួរបដិសេធដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលមានវិការៈ ហើយបង្វិលសំណុំរឿងត្រឡប់ទៅសហចៅក្រមស៊ើបអង្កេត ដោយមានដីកាបង្គាប់ឲ្យចេញដីកាដំណោះស្រាយរួមគ្នា ស្របទៅតាមច្បាប់ជាធរមាន ដោយកត់សម្គាល់ថា ការខ្វែងយោបល់គ្នាទាំងឡាយណាដែលនៅមាន ចាំបាច់ត្រូវដោះស្រាយដោយផ្តល់ជាប្រយោជន៍ដល់លោក យឹម ទិត្យ[86]។ អង្គ

[85] សេចក្តីពិចារណា សំណុំរឿង ០០៤/២ កថាខណ្ឌ ១២៤។

[86] គោលការណ៍ វិមតិសង្ស័យ និងបានជាប្រយោជន៍ដល់ជនជាប់ចោទ គឺជាធាតុផ្សំស្នូលនៃសច្ចធារណ៍និរទោស ដែលត្រូវបានធានាតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងច្បាប់អន្តរជាតិ។ គោលការណ៍នេះ គឺថា វិមតិសង្ស័យត្រូវតែបកស្រាយជាប្រយោជន៍ដល់ជនជាប់ចោទ ហើយត្រូវអនុវត្តចំពោះភាពមិនច្បាស់លាស់ណា ដែលកើតឡើងទាំងនៅក្នុងការសម្រេចលើអង្គហេតុនៃភស្តុតាង និងការសម្រេចលើការទទួលខុសត្រូវជាបុគ្គល។ *សូមមើល* រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា ៣៨ (“វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ”), ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៥១ (“វិមតិសង្ស័យត្រូវតែបានជាអត្ថប្រយោជន៍ដល់ជនជាប់ចោទជានិច្ច”)។ សំណុំរឿង ០០២/០២ សាលក្រម ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ២១ និង៣០១៤ (អង្គជំនុំជម្រះបានដោះស្រាយភាពមិនច្បាស់លាស់លើអង្គហេតុ "ដោយអនុវត្តការបកស្រាយ ដែលផ្តល់ជាប្រយោជន៍បំផុត ចំពោះជនជាប់ចោទ ដោយអនុលោមទៅតាមគោលការណ៍ វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ"។ សំណុំរឿង ០០២/០១ សាលក្រម ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ ២២ (“បន្ទាប់ពីបានវាយតម្លៃទៅលើភស្តុតាងដោយមានសំអាងហេតុរួច អង្គជំនុំជម្រះនឹងធ្វើការបកស្រាយវិមតិសង្ស័យដោយផ្តល់ប្រយោជន៍ដល់ជនជាប់ចោទ”)។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១១ ឯកសារ E50/3/1/4 កថាខណ្ឌ ៣១ (“អង្គជំនុំជម្រះតុលាការកំពូល បញ្ជាក់យ៉ាងមុតមាំថា គោលការណ៍នេះ [វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ] ដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលកើតចេញពីគោលការណ៍ ការសន្មតទុកជាមុនថាគ្មានទោស និងដែលមានចែងជាមូលដ្ឋាន ក្នុងប្រព័ន្ធគតិយុត្តិរបស់កម្ពុជាផងដែរនោះ មានមុខងារជាចម្បងក្នុងការបង្ហាញឲ្យឃើញនូវការយល់ដឹងជាស្វ័យប្រវត្តិ ក្នុងករណីដែលពុំមានភស្តុតាងលុបបំបាត់ ភាពមន្ទិលសង្ស័យ”)។ កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, មាត្រា ១៤(២), អង្គបុរេជំនុំជម្រះ២ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ រដ្ឋអាជ្ញា *តទល់នឹង Bemba* (ICC-01/05-01/08-424) (“សេចក្តីសម្រេចអនុលោម

បុរេជំនុំជម្រះបានសម្រេចថា អង្គជំនុំជម្រះ "នឹងបញ្ជូនសេចក្តីសម្រេចនេះ ឲ្យទៅសហចៅក្រមស៊ើបអង្កេត ធ្វើការពិចារណាសាជាថ្មី" នៅពេលដែលអង្គជំនុំជម្រះកំណត់បានអំពីកំហុសឆ្គង ឬការរំលោភបំពានជាមូលដ្ឋាន ទៅលើការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត[87]។ ការចេញដីកាដំណោះស្រាយពីរ ដាច់ពីគ្នាដោយខុសច្បាប់ អាចចាត់ទុកថាជាកំហុសឆ្គង ដែលមានលក្ខណៈបែបនេះ។ ឧបាស្រ័យនេះល្អជាងការដែលអង្គបុរេជំនុំជម្រះត្រូវប្តូរដីកាសម្រេចផ្ទាល់របស់ខ្លួន ដែលអង្គបុរេជំនុំជម្រះនឹងអនុវត្ត "តែក្នុងករណីពិសេសប៉ុណ្ណោះ"[88] ដោយសារតែសហចៅក្រមស៊ើបអង្កេតធ្វើសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិខ្លួន ដោយមាន "ការយល់ដឹងជ្រៅជ្រះទៅលើសំណុំរឿង"[89]។ ដូចដែលអង្គបុរេជំនុំជម្រះបានទទួលស្គាល់នាពេលកន្លងមក អង្គបុរេជំនុំជម្រះ

---

តាម មាត្រា ៦១(៧)(ក) និង(ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីការចោទប្រកាន់របស់រដ្ឋអាជ្ញា ប្រឆាំង Jean-Pierre Bemba Gombo" ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ កថាខណ្ឌ ៣១ (ជាចុងក្រោយ ក្នុងការធ្វើការសម្រេចនេះ [លើកការគាំទ្រដល់បទចោទ] អង្គជំនុំជម្រះសូមគូសបញ្ជាក់ថា ដោយគោរពតាមគោលការណ៍ វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ ជាធាតុផ្សំនៃសច្ចធារន៍និរទោស ដែលជាគោលការណ៍ទូទៅមួយ ដែលត្រូវអនុវត្តក្នុងករណីចាំបាច់ នៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី រួមទាំងដំណាក់កាលមុនពេលជំនុំជម្រះ")។

[87] សេចក្តីពិចារណា សំណុំរឿង ០០៤/២ កថាខណ្ឌ ៣០ ដកស្រង់ សំណុំរឿង ០០៤/១ *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ)* ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារD308/3/1/20 កថាខណ្ឌ ២២។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងដីកាសម្រេចបដិសេធសំណើសុំ ស្តាប់ចម្លើយបុគ្គលដែលមានឈ្មោះ ក្នុងសំណើសុំបំពេញកិច្ចស៊ើបសួរ លើការរៀបការដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១០ ឯកសារ D310/3/1/3 កថាខណ្ឌ ១៥ ដល់១៦។ សំណុំរឿង ០០២ *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ សហចៅក្រមស៊ើបអង្កេត អំពីការណែនាំឲ្យពិចារណាឡើងវិញ លើសំណើសុំ D153, D172, D174, D178,* និង *D284* ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១០ ឯកសារ D300/1/7 កថាខណ្ឌ ១៩ និង២៦។

[88] សេចក្តីពិចារណា សំណុំរឿង ០០៤/២, កថាខណ្ឌ ៣០ ដកស្រង់ សំណុំរឿង ០០២ សាលដីកាស្តីពីការពិចារណាឡើងវិញ ទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាសម្រេចរបស់ សហចៅក្រមស៊ើបអង្កេត ទៅលើសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើង ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១០ ឯកសារD365/2/17 កថាខណ្ឌ ៦៧។

[89] សំណុំរឿង ០០២ សាលដីកាស្តីពីការពិចារណាឡើងវិញ ទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសំណើសុំដាក់បញ្ចូល ឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើង ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១០ ឯកសារD365/2/17 កថាខណ្ឌ ៦៧។

មិនបាន "កំណត់" ឬ "មានអំណាចបំពេញកិច្ចស៊ើបសួរ" នៅក្នុងបរិបទនៃលក្ខណៈពិសេសរបស់សំណុំរឿងនៃ អ.វ.ត.ក "ពាក់ព័ន្ធនឹងការស៊ើបអង្កេតក្នុងទំហំធំ និងជាប់ពាក់ព័ន្ធនឹងករណីច្រើនលើសលប់"[90]។

៣៩. ជាជម្រើសផ្សេងមួយទៀត អង្គបុរេជំនុំជម្រះមានសិទ្ធិចេញដីកាដំណោះស្រាយជាឯកច្ឆ័ន្ទដោយខ្លួនឯង ដោយចោទប្រកាន់លោក យឹម ទិត្យ បញ្ជូនទៅជំនុំជម្រះ ឬលើកលែងចោទប្រកាន់ប្រឆាំងនឹងរូបគាត់។ ដូចដែលអង្គបុរេជំនុំជម្រះបានទទួលស្គាល់ អង្គជំនុំជម្រះ "បំពេញតួនាទីជាសភាស៊ើបសួរ តាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុង អ.វ.ត.ក" ហើយនៅពេលមានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ "វិធាន ៧៩(១) នៃវិធានផ្ទៃក្នុងស្នើឡើងថា អង្គបុរេជំនុំជម្រះមានអំណាចចេញដីកាដំណោះស្រាយថ្មីមួយ ឬចេញដីកាដំណោះស្រាយដែលបានកែប្រែរួច។ ដីកានេះនឹងយកមកធ្វើជាមូលដ្ឋាននៃការជំនុំជម្រះ"[91]។ តាមភាពសមហេតុផល អង្គបុរេជំនុំជម្រះក៏មានសិទ្ធិក្នុងការចេញដីកាដំណោះស្រាយថ្មី ឬដីកាដំណោះស្រាយដែលបានកែប្រែរួច លើកលែងការចោទប្រកាន់សំណុំរឿងនេះ។ ការអនុវត្តបែបនេះគឺស្របទៅតាមនិយមន័យនៃដីកាដំណោះស្រាយក្នុងសទ្ទានុក្រមនៃវិធានផ្ទៃក្នុងដែលលើកឡើងថា "ដីកាចុងក្រោយដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ នៅពេលបញ្ចប់ដំណើរការស៊ើបសួរ ដែលអាចជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬ ដីកាលើកលែងចោទប្រកាន់"[92]។

៤០. នៅក្នុងករណីដែលអង្គបុរេជំនុំជម្រះសម្រេចចេញដីកាដំណោះស្រាយផ្ទាល់ អង្គជំនុំជម្រះគួរពិចារណាទៅលើ *ដីកាសន្និដ្ឋានស្ថាពរ* របស់សហព្រះរាជអាជ្ញាជាតិ *ទាក់ទងនឹងករណី យឹម ទិត្យ អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង*[93] និង *ដីកាសន្និដ្ឋានស្ថាពររបស់ សហព្រះរាជអាជ្ញាអន្តរជាតិ*

---

[90] សំណុំរឿង ០០២ *សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេច លើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុក នៅក្នុងឃ្លាំងផ្ទុកឯកសាររួម* ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/3/6 កថាខណ្ឌ ២៤។

[91] សេចក្តីពិចារណា សំណុំរឿង ០០៤/២, កថាខណ្ឌ ៣០។ សំណុំរឿង ០០១ *សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច"* ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ D99/3/42 កថាខណ្ឌ ៤០។ សំណុំរឿង ០០៤/១ *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ)* ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារD308/3/1/20 កថាខណ្ឌ ២២។

[92] វិធានផ្ទៃក្នុង សទ្ទានុក្រម ទំព័រ ៨៣។

[93] ដីកាសន្និដ្ឋានស្ថាពរ ទាក់ទងករណី យឹម ទិត្យ អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ ឯកសារ D378/1។

*ប្រឆាំងនឹង យឹម ទិត្យ អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង*[94] និង *ចម្លើយតបរួមរបស់ យឹម ទិត្យ ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ*[95]។ ទោះបីជាអង្គបុរេជំនុំជម្រះ ដូចគ្នានឹងសហចៅក្រមស៊ើបអង្កេត មិនមានកាតព្វកិច្ច ដោយសារណារបស់ភាគី ក្នុងការចេញដីកាដំណោះស្រាយថ្មីក្តី[96] តែប្រាកដណាស់ ពួកគាត់នឹងទទួលបានផលប្រយោជន៍ពីទស្សនៈលម្អិតរបស់ភាគីនានាលើកស្តុតាងនៅក្នុងសំណុំរឿង ប្រវត្តិនៃការចរចាកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក ព្រមទាំងច្បាប់ និងយុត្តិសាស្ត្រ ពាក់ព័ន្ធនឹងការប្រើប្រាស់ឆន្ទានុសិទ្ធិក្នុងការសម្រេចថាតើលោក យឹម ទិត្យ ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដែរឬអត់។

៤១. ដូចដែលអង្គបុរេជំនុំជម្រះបានសម្រេចជាឯកច្ឆ័ន្ទនៅក្នុងសំណុំរឿង ០០៤/២ សិទ្ធិអំណាចក្នុងការត្រួតពិនិត្យឡើងវិញរបស់អង្គជំនុំជម្រះ ក្នុងនាមជាសភាស៊ើបសួរ គឺ “ធានាថា លក្ខខណ្ឌនៃការចេញដីកាដំណោះស្រាយ និងការស៊ើបអង្កេតជាបឋម អនុលោមតាមវិធាន ២១ និងវិធាន

---

[94] ដីកាសន្និដ្ឋានស្ថាពររបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹង យឹម ទិត្យ អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ D378/2។

[95] ចម្លើយតបរួមរបស់ យឹម ទិត្យ ទៅនឹងដីកាសន្និដ្ឋានស្ថាពរ របស់សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D378/5។

[96] វិធាន ៦៧(១) នៃវិធានផ្ទៃក្នុង “សហចៅក្រមស៊ើបអង្កេតត្រូវបញ្ចប់កិច្ចស៊ើបសួរ ដោយចេញដីកាដំណោះស្រាយថាត្រូវចោទប្រកាន់ និងបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់។ ដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាមិនចងសហចៅក្រមស៊ើបអង្កេតឡើយ”។ *សូមមើលផងដែរ* សំណុំរឿង ០០២ *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី* ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D390/1/2/4 កថាខណ្ឌ ២, ៣, ៥, ១៣ និងទំព័រ ៣។នៅក្នុងសំណុំរឿង ០០២ សហចៅក្រមស៊ើបអង្កេតបានបដិសេធសំណើរបស់ អៀង សារី សុំបន្ថែមទំព័រ និងពេលវេលាកំណត់ ក្នុងការដាក់ចម្លើយតបចំពោះដីកាសន្និដ្ឋានស្ថាពរ ដោយលើកសំអាងហេតុថា “វិធានផ្ទៃក្នុងមិនបានចែងអំពីចម្លើយតបចំពោះដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាឡើយ ហើយបន្ទាប់មកបានបដិសេធមិនទទួលយកការដាក់ចម្លើយតបចំពោះដីកាសន្និដ្ឋានស្ថាពរ។ នៅក្នុងបណ្តឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះបានបង្គាប់ដល់សហចៅក្រមស៊ើបអង្កេតឱ្យដាក់ជាបន្ទាន់នូវចម្លើយតប ចំពោះដីកាសន្និដ្ឋានស្ថាពរ ទៅក្នុងសំណុំរឿង ដោយលើកសំអាងហេតុថា សហចៅក្រមស៊ើបអង្កេតអាចទទួលប្រយោជន៍បានតែក្នុងករណី ទទួលយកសារណាពីក.ស.ព និងសហមេធាវី ហើយថា “ស្ថាប័នតុលាការគឺមិនជាប់កាតព្វកិច្ច ដោយសារណារបស់ភាគីឡើយ”។

៧៦ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក និងមាត្រា ២៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា”[97]។ “អំណាចត្រួតពិនិត្យនេះមានសារៈសំខាន់ណាស់ និងកំណត់ច្បាស់ថា “គ្មានបញ្ហាណាមួយដែលពាក់ព័ន្ធនឹងកំហុសនីតិវិធីបែបនេះ អាចត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូលឡើយ”[98]។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះចាំបាច់ត្រូវតែអនុវត្តដោយច្បាស់ លាស់នាពេលនេះ អនុលោមទៅតាមមតិជាឯកច្ឆ័ន្ទរបស់ខ្លួន ក្នុងការកែតម្រូវចំពោះកិច្ចនីតិវិធីដែលខុសច្បាប់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។

## សំណើសុំ

**អាស្រ័យហេតុនេះ** ផ្អែកលើហេតុផលទាំងអស់ដែលបានលើកឡើងខាងលើ មេធាវីការពារក្តីស្នើដោយគោរពចំពោះអង្គបុរេជំនុំជម្រះ នៅក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន និងដើម្បីប្រយោជន៍យុត្តិធម៌៖

(១) **បដិសេធ**ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និង

(២) **បដិសេធ**ទាំងស្រុងចំពោះដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលមានវិការៈ ហើយលើកលែងការចោទប្រកាន់ប្រឆាំងនឹងលោក យឹម ទិត្យ ឬ

(៣)**បដិសេធ**ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលមានវិការៈ ហើយបង្វិលសំណុំរឿងត្រឡប់ទៅសហចៅក្រមស៊ើបអង្កេត ដោយចេញដីកាបង្គាប់ឲ្យចេញដីកាដំណោះស្រាយរួមគ្នាមួយ អនុលោមតាមច្បាប់ជាធរមាន ដោយកត់សម្គាល់ថា រាល់ការខ្វែងយោបល់គ្នាដែលនៅមាន ចាំបាច់ត្រូវដោះស្រាយដោយផ្តល់ប្រយោជន៍ដល់លោក យឹម ទិត្យ ឬ

(៤)**បដិសេធ**ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលមានវិការៈ ហើយធ្វើការវាយតម្លៃទៅលើសំណុំរឿង ០០៤ ដោយផ្ទាល់ និងចេញដីកាដំណោះស្រាយផ្ទាល់របស់អង្គជំនុំជម្រះ ដោយចោទប្រកាន់លោក យឹម ទិត្យ បញ្ជូនទៅជំនុំជម្រះ ឬលើកលែងចោទប្រកាន់ប្រឆាំងរូបគាត់។

[97] សេចក្តីពិចារណា សំណុំរឿង ០០៤/២ កថាខណ្ឌ ៥០។

[98] សេចក្តីពិចារណា សំណុំរឿង ០០៤/២ កថាខណ្ឌ ៥២ *ដកស្រង់* វិធាន ៧៦(៧) នៃវិធានផ្ទៃក្នុង។

សូម លោកចៅក្រម ទទួលយកការឆ្លើយតបនេះដោយក្តីគោរព។

______________________ ______________________

ស៊ូ មុស្សេរ៉ី Suzana TOMANOVIĆ

សហមេធាវីការពារក្តីលោក យឹម ទិត្យ

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០